# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានវិស្វកម្មកសិកម្ម

## គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន

**Climate-Friendly Agribusiness Value Chains Sector Project (CFAVC)**

**ADB Loan No. 3661-CAM (COL), 8346-CAM (EF) and Grant No. 0579 (EF)**

# ឯកសារមេរៀនបណ្តុះបណ្តាល

# ស្តីពី

# ការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ

## (Technical Manual on Laser Land Leveling)



រៀបចំដោយ៖ នាយកដ្ឋានវិស្វកម្មកសិកម្ម (DAEng)

**ឆ្នាំ ២០២០**

## អ្នករៀបរៀង

១. លោក **ទឹម ប្រុស** — អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

២. លោក **ហ៊ុយ សុនាថ** — ប្រធានការិយាល័យវិស្វកម្ម និងកំណែទម្រង់ដីកសិកម្ម នៃនាយកដ្ឋានវិស្វកម្មកសិកម្ម

៣. លោក **ភេ ណារិន** — ប្រធានការិយាល័យបណ្តុះបណ្តាល និងអភិវឌ្ឍន៍សហគមន៍កសិកម្មនៃនាយកដ្ឋានវិស្វកម្មកសិកម្ម

៤. កញ្ញា **ខុម សុខា** — អនុប្រធានការិយាល័យវិស្វកម្ម និងកំណែទម្រង់ដីកសិកម្មនៃនាយកដ្ឋានវិស្វកម្មកសិកម្ម

៥. លោក **សរ សានទី** — មន្ត្រីការិយាល័យវិស្វកម្ម និងកំណែទម្រង់ដីកសិកម្ម នៃនាយកដ្ឋានវិស្វកម្មកសិកម្ម

៦. លោក **ថោង រចនា** — មន្ត្រីកិច្ចសន្យា ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានវិស្វកម្មកសិកម្ម

## អ្នកផ្តល់យោបល់កែសម្រួល

១. លោក **ងិន កុសល** — ប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

២. លោក **ញ៉ែម សុខា** — អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

៣. លោក **សេង ទុយ** — អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

៤. លោក **សេង សារ៉ាត់** — អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

៥. លោក **ជា សុវណ្ណឌីណា** — អនុប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAEng/GDA/MAFF)

៦. លោក លោកស្រី — ជាមន្ត្រី នៃនាយកដ្ឋានវិស្វកម្មកសិកម្ម ។

## អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CARDI | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CIAP | គម្រោងកម្ពុជា អ៊ុីរីអូស្ត្រាលី |
| DAP | ជី ដេ អា ប៉េ (ឌីអាម៉ូញ៉ូមផូស្វាត) |
| DAEng | នាយកដ្ឋានវិស្វកម្មកសិកម្ម |
| DC | ចរន្តជាប់ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MAFF-NIO | អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| Rice-SDP | កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ |
| PSI | ខ្នាតសម្ពាធ ក្នុង១អ៊ីងការ៉េ |
| V | ខ្នាតរបស់តង់ស្យុងគិតជាវ៉ុល |
| m | ម៉ែត្រ |
| គ.ក្រ | គីឡូក្រាម |
| គ.ម | គីឡូម៉ែត្រ |
| ម | ម៉ែត្រ |
| ម.ម | មិល្លីម៉ែត្រ |
| ម៉ | ម៉ោង |
| ហ.ត | ហិកតា |
| ស.ម | សង់ទីម៉ែត្រ |

# ១. សេចក្ដីផ្ដើម ( Introduction )

សៀវភៅណែនាំនេះ ពន្យល់ពីអត្ថប្រយោជន៍នៃការកៀរពង្រាបដីនៅក្នុងវាលស្រែ ហើយនឹងជួយអភិវឌ្ឍជំនាញដល់ប្រតិបត្តិករក្នុងការប្រើបច្ចេកវិទ្យាទំនើប ដើម្បីសម្រេចបាននូវដីស្រែកសិកម្មមួយដែលមានផ្ទៃដីរាបស្មើ។ ទន្ទឹមនេះ ក៏ផ្ដល់នូវចំណេះដឹងផងដែរ លើការងាររៀបចំដីដោយគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្មឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។

## ១.១ សនិទានភាព (Rationale)

ផលប្រយោជន៍សេដ្ឋកិច្ចនៃការរៀបចំកៀរពង្រាបដីកសិកម្មបានស្មើល្អ គឺជាផ្នែកមួយនៃការរៀបចំដី។ ការរៀបចំកៀរពង្រាបដីមិនបានស្មើល្អមុនការដាំដំណាំ វាជះឥទ្ធិពលដ៏សំខាន់មួយទៅលើការគ្រប់គ្រងដំណាំនិងទិន្នផលដំណាំផងដែរ ។ ដោយហេតុថាកសិករត្រូវចំណាយថវិកានិងពលកម្មបន្ថែមទៀត ដើម្បីបង្កើតនិងរក្សាបាននូវផលដំណាំ ហើយនឹងទទួលបានប្រាក់ចំណូលតិចពីការលក់កសិផលប្រសិនបើដីស្រែរបស់គាត់មិនត្រូវបានកៀរពង្រាបឱ្យបានស្មើនោះទេ។ ដីស្រែដែលមិនបានកៀរពង្រាប គឺកម្រិតទឹកគ្របដណ្ដប់មិនស្មើគ្នា មានន័យថាដីស្រែនោះមានតម្រូវការទឹកបន្ថែមទៀត ដើម្បីឱ្យដីស្រែទាំងមូលសើមសម្រាប់ការរៀបចំដីនិងដាំដំណាំ។ តម្រូវការទឹកបន្ថែមទៀត ទាមទារឱ្យចំណាយពេលនិងថវិកាបន្ថែមទៀត ដើម្បីស្រោចស្រពដីស្រែឬចំពោះស្រែវស្សា(rainfed farms) ត្រូវតែរង់ចាំរហូតដល់មានភ្លៀងធ្លាក់ជាបន្តបន្ទាប់។ នេះជាពេលវេលាបន្ថែមមួយទៀតនៅក្នុងការគ្រប់គ្រងទឹក ធ្វើឱ្យពេលវេលាសម្រាប់ការងារបង្កបង្កើនផលតិចដើម្បីបំពេញការងារប្រតិបត្តិផ្សេងៗនិងការរីកលូតលាស់ដំណាំ។ ដីស្រែដែលមិនរាបស្មើធ្វើឱ្យដើមស្រូវដុះមិនបានស្មើគ្នា មានស្មៅដុះច្រើននិងដំណាំទុំមិនស្រុះគ្នា ហើយជាជម្រកសត្វបំផ្លាញរស់នៅជាពិសេសទំហំគ្រាប់មិនស្មើគ្នាហើយពេលយកចូលម៉ាស៊ីនកិនស្រូវទទួលបានអង្ករដើមតិច។ កត្តាទាំងអស់នេះ បានធ្វើឱ្យទិន្នផលនិងគុណភាពដំណាំទាប ហើយកាត់បន្ថយចំណូលពីសក្ដានុពលដំណាំ (potential income from the crop)។ ប្រសិទ្ធភាពនៃការធ្វើដីស្រែឱ្យបានរាបស្មើ និងមានភ្លឺសមស្របងាយស្រួលក្នុងការគ្រប់គ្រងផលដំណាំ ដូចជាសន្សំសំចៃទឹក ដើមស្រូវទទួលដីបានស្មើ កាត់បន្ថយការបំផ្លិចបំផ្លាញពីសត្វចង្រៃធ្វើឱ្យប្រសើរឡើងនូវផលដំណាំ កាត់បន្ថយពេលវេលាប្រតិបត្តិផ្សេងៗទៀតងាយស្រួលក្នុងការប្រមូលផលហើយបង្កើនទាំងគុណភាពគ្រាប់ធញ្ញជាតិនិងទិន្នផលដំណាំ។

## ១.២ គោលដៅ (Objectives)

- កំណត់អត្តសញ្ញាណនិងយល់ដឹងពីសមាសភាគប្រតិបត្តិការនៃប្រព័ន្ធវាស់ស្ទង់ដីស្រែ ដោយឡាហ្សែរ
- អនុវត្តការធ្វើអង្កេតឋានលេខាដី (topographic survey) ដោយប្រើប្រព័ន្ធឡាហ្សែរមួយ
- រៀបចំនិងធ្វើឱ្យកម្រិតផ្ទៃដីស្រែបានរាបស្មើ ដោយប្រើប្រព័ន្ធវាស់ស្ទង់ដីដោយឡាហ្សែរ
- រិះរកដំណោះស្រាយបញ្ហាប្រព័ន្ធវាស់ស្ទង់ដីដោយឡាហ្សែរ (laser controlled leveling system)
- យល់ដឹងពីបច្ចេកទេសនៃការរៀបចំដីដោយគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម។

ប្រសិទ្ធភាពនៃការកៀរពង្រាបដី គឺជួយកាត់បន្ថយការងារប្រតិបត្តិនៅក្នុងបច្ចេកទេសដាំដុះ (crop establishment) ការគ្រប់គ្រងដំណាំ បង្កើនទិន្នផល និងគុណភាពដំណាំ។ ដីកៀរបានរាបស្មើធ្វើឱ្យប្រសើរឡើងដល់បរិមាណទឹក ដែលគ្របដណ្តប់ដីស្រែដូចជា៖

- កាត់បន្ថយបរិមាណទឹកដែលត្រូវការសម្រាប់ការស្រោចស្រពដំណាំ
- ធ្វើឱ្យប្រសើរឡើងដល់បច្ចេកទេសដាំដុះ (crop establishment) (សម្រាប់ម៉ាស៊ីនកសិកម្មនិងឧបករណ៍កសិកម្មមុនពេល និងក្រោយប្រមូលផល)
- កាត់បន្ថយពេលវេលាក្នុងការបំពេញការងារផ្សេងៗ
- កាត់បន្ថយបញ្ហាស្មៅ និងបំផ្លាញជម្រកសត្វកណ្តុរ
- កាត់បន្ថយការបាត់បងពេលប្រមូលផល(សម្រាប់ម៉ាស៊ីនច្រូតស្រូវស្វ័យប្រវត្តិ)
- ធ្វើឱ្យប្រសើរឡើងដល់គ្រាប់ធញ្ញជាតិឱ្យមានទម្រង់និងទំហំដូចគ្នានៅដំណាក់កាលទុំ។

### ១.៣ ទិន្នផល (Yield)

តាមរយៈការស្រាវជ្រាវបានបង្ហាញថា ការកើនឡើងនៃទិន្នផលស្រូវ គឺដោយសារតែដីស្រែកៀរពង្រាបបានល្អផងដែរ។ តារាងខាងក្រោមនេះ បង្ហាញពីលទ្ធផលនៃការពិសោធន៍លើការកៀរពង្រាបដីស្រែនៅក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩។

**តារាងទី១** លទ្ធផលនៃការពិសោធន៍លើការកៀរពង្រាបដីនៅក្នុងប្រទេសកម្ពុជា

| ឆ្នាំនិងប្រតិបត្តិករ | ចំនួនដីស្រែ | ទិន្នផលស្រូវ (តោន/ហិកតា) | |
|---|---|---|---|
| | | ស្រែដែលបានកៀរ | ស្រែមិនបានកៀរ |
| 1996 | 16 | 3,40 | 2,67 |
| 1997 | 14 | 2,27 | 1,46 |
| 1998 | 37 | 2,72 | 2,36 |
| 1999 (CARDI) | 35 | 2.34 | 2.00 |
| មធ្យមភាគ | | 2,72 | 2,19 |

លទ្ធផលនៃការធ្វើពិសោធន៍កៀរពង្រាបដីស្រែធ្វើឡើងដោយគម្រោងកម្ពុជា អូស្ត្រាលី (CIAP) នៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩។

តារាងនៃលទ្ធផលនេះ សម្រាប់ពូជស្រូវដូចគ្នានិងការប្រើប្រាស់ជីដូចគ្នា បង្ហាញថាការកើនឡើងជាមធ្យមនៃទិន្នផលដំណាំស្រូវ **គឺ២៤ភាគរយ** ឬ៥៣០គីឡូក្រាមស្រូវក្នុងមួយហិកតា។ នៅក្នុងការធ្វើពិសោធន៍ពីរ ដែលបានធ្វើឡើងនៅតំបន់ផ្សេងគ្នាបានឱ្យឃើញថាមានការជាប់ទាក់ ទងគ្នា (strong correlation) ខ្លាំងរវាងភាពមិនស្មើរបស់ដី (levelness of the land) និងទិន្នផលស្រូវ។ ការជាប់ទាក់ទងគ្នានេះ មានបង្ហាញនៅក្នុងគំនូសតាងដូចខាងក្រោមនេះ៖




រូបទី១ ទំនាក់ទំនងរវាងកម្រិតភាពស្មើនៃដីនិងទិន្នផល

## ១.៤ ការត្រួតពិនិត្យស្មៅ (Weed Control)

ការកើនឡើងនេះ គឺដោយសារតែមានការត្រួតពិនិត្យស្មៅបានល្អ ធ្វើឱ្យប្រសើរឡើងដល់ការផ្គត់ផ្គង់ទឹកពីដីដែលបានកៀរពង្រាបដោយអាចកាត់បន្ថយស្មៅរហូតដល់ទៅ៤០%។ ការកាត់បន្ថយស្មៅដុះក្នុងស្រែ ដោយគ្រាប់ស្មៅមានរយៈពេលតិចក្នុងការដុះលូតលាស់។ ការកាត់បន្ថយអាចសម្រេចបានពី ២១ ពលកម្ម.ថ្ងៃ/ហិកតា មកត្រឹម ៥ នាក់.ថ្ងៃ/ហ.ត។ នេះតំណាងឱ្យការកាត់បន្ថយរហូតដល់ ១៦ នាក់.ថ្ងៃ/ហ.ត គឺថយចុះ ៧៥% នៃកម្លាំងពលកម្មដែលត្រូវការសម្រាប់ការងារកំចាត់ស្មៅ។

## ១.៥ ប្រតិបត្តិការលើកសិដ្ឋាន (Farm Operation)

ការកៀរពង្រាបដីអាចមានលទ្ធភាពអនុវត្តលើកសិដ្ឋានធំៗផងដែរ។ កសិដ្ឋានធំៗបង្កើនផ្ទៃដីដាំដុះ និងធ្វើឱ្យប្រសើរដល់ប្រសិទ្ធភាពប្រតិបត្តិការទៀតផង។ ការបង្កើនទំហំដីស្រែពី ០,១ហ.ត ទៅ ០,៥ ហ.ត បង្កើនផ្ទៃដីដាំដុះបានរវាងពី ៥% និង ៧%។ ការកើនឡើងផ្ទៃដីដាំដុះផ្តល់ឱ្យកសិករនូវជម្រើស ដើម្បីកែសម្រួលទម្រង់ដីស្រែឡើងវិញ (reshape) ដែលអាចកាត់បន្ថយពេលវេលាប្រតិបត្តិការរវាងពី ១០% ទៅ ១៥%។

## ១.៦ ការអនុវត្តន៍ព្រោះគ្រាប់ពូជ (Seeding Practices)

ដីរាបស្មើធ្វើឱ្យដំណុះគ្រាប់ដុះស្មើគ្នាបានល្អ កាត់បន្ថយពេលវេលាសម្រាប់ការដាំដុះ សម្រាប់ការស្ទូង និងសម្រាប់ការព្រោះគ្រាប់ដោយផ្ទាល់ (direct seeding)។ ការកៀរពង្រាបដីផ្តល់នូវឱកាសកាន់តែច្រើន

ថែមទៀតលើការព្រោះគ្រាប់ដោយផ្ទាល់។ ការកាត់បន្ថយកម្លាំងពលកម្ម ដែលអាចធ្វើបានដោយការផ្លាស់ប្តូរពីការស្ទូងទៅការព្រោះគ្រាប់ដោយផ្ទាល់ គឺមានប្រមាណ ៣០ នាក់.ថ្ងៃ/ហិកតា។

### ១.៧ ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក (Efficiency of Water Use)

កសិករដាំស្រូវដោយប្រើកម្លាំងអូសទាញដោយសត្វពាហនៈ ឬក៏គោយន្ត គឺពឹងផ្អែកលើទឹកដើម្បីបង្ហូរចូលក្នុងស្រែមុនពេលចាប់ផ្តើមរៀបចំដីស្រែ។ ភាពខុសគ្នាជាមធ្យមនៃកម្ពស់រវាងផ្នែកខ្ពស់បំផុតនិងផ្នែកទាបបំផុតនៃដីស្រែនៅក្នុងទ្វីបអាស៊ី គឺ ១៦០ មិល្លីម៉ែត្រ(ម.ម)។ នេះមានន័យថា នៅក្នុងដីស្រែដែលមិនទាន់កៀរ (unleveled) តម្រូវការទឹកពី ៨០ មិល្លីម៉ែត្រ ទៅ១០០ មិល្លីម៉ែត្រ ត្រូវតែតម្កល់ទុកនៅក្នុងស្រែដើម្បីឱ្យទឹកគ្របដណ្តប់ពេញលេញ។ នេះគឺជិត ១០% បន្ថែមនៃតម្រូវការទឹកសរុប ដែលត្រូវការសម្រាប់ការដុះលូតលាស់នៃដំណាំ។ ដីស្រែរាបស្មើ គឺមានប្រសិទ្ធភាពណាស់ចំពោះស្រែជាថ្នាក់ៗ (Terraces) ដែលធ្វើឱ្យទឹកអាចហូរពីស្រែដែលខ្ពស់ដើម្បីប្រើប្រាស់សម្រាប់ស្រែដែលទាបក្នុងការរៀបចំដី ការលូតលាស់នៃដំណាំ (plant establishment) និងការស្រោចស្រព។




រូបទី២ ប្រសិទ្ធភាពនៃការគ្រប់គ្រងទឹកក្នុងស្រែ

## ២. ប្រព័ន្ធនៃការកៀរពង្រាបដី ( Systems of Land leveling )

សត្វពាហនៈ ដូចជាគោក្របី គោយន្ត និងត្រាក់ទ័រមានប៉ុងមុខ (4 wheel tractor) អាចត្រូវបានប្រើជាប្រភពថាមពល ដើម្បីរៀបចំដីស្រែឱ្យបានរាបស្មើ។ ប្រព័ន្ធផ្សេងៗទៀត តម្រូវការលក្ខខណ្ឌដីស្រែ និងពេលវេលាប្រតិបត្តិការផ្សេងគ្នា ដើម្បីបំពេញកិច្ចការឱ្យបានចប់។

### ២.១ វិធីកៀរពង្រាបដីដោយប្រើសត្វពាហនៈ (land leveling by draft animals)

បច្ចេកទេសកៀរពង្រាបដីដោយសត្វពាហនៈ (គោ ក្របី) ប្រើអូសរនាស់ គឺទាមទារឱ្យមានទឹកដក់នៅក្នុងស្រែជាមុនសិន ហើយអាចចំណាយពេលប្រមាណ១២ ថ្ងៃក្នុង ១ហិកតាដី។



រូបទី៣ ការកៀរពង្រាបដីដោយសត្វពាហនៈ

## ២.២ វិធីកៀរពង្រាបដីដោយប្រើគោយន្តភ្ជាប់បន្ទះក្តារកៀរ

### (2-wheel tractor attached leveling board)

ដូចគ្នាទៅនឹងការកៀរពង្រាបដីដោយសត្វពាហនៈផងដែរ បច្ចេកទេសកៀរពង្រាបដីដោយប្រើគោយន្ត គឺទាម ទារឱ្យមានទឹកដក់សព្វដីស្រែ ហើយបច្ចេកទេសកៀរដីរបៀបនេះអាចចំណាយពេលប្រមាណពី ៧ ទៅ ៨ ថ្ងៃក្នុង ១ ហិកតា។



រូបទី៤ ការកៀរពង្រាបដីដោយគោយន្តភ្ជាប់បន្ទះក្តារកៀរ

## ២.៣ វិធីកៀរពង្រាបដីដោយប្រើត្រាក់ទ័រភ្ជាប់ខ្សៀរកៀរដីពីក្រោយ

### (4-wheel tractor using rear mounted leveling board)

ត្រាក់ទ័រមានប៉ុងមុខ គឺមានប្រសិទ្ធភាពសម្រាប់ការកៀរពង្រាបដីឱ្យស្មើទាំងលើដីសើមនិងស្ងួត។ ដីសើមត្រូវបានកៀរពង្រាបល្អបំផុតជាមួយប៉ែល (blade) បំពាក់ពីក្រោយត្រាក់ទ័រ។ ដីស្ងួតត្រូវបានកៀរពង្រាបល្អបំផុតដោយដាក់ធុងអូសកៀរដីពីក្រោយ (drag bucket) ត្រាក់ទ័រ ។ អត្រាធ្វើការរបស់ត្រាក់ទ័រ គឺពឹងផ្អែកលើសមត្ថភាពរបស់ត្រាក់ទ័រ និងចំនួនអាចម៍ដីដែលត្រូវចូកចេញ។ វាត្រូវការពេលប្រមាណជា ៨ ម៉ោង សម្រាប់កៀរដីឱ្យស្មើ ១ ហិកតា ជាមួយប៉ែល (blade) បំពាក់ពីមុខត្រាក់ទ័រ។ ការងារនេះអាចកាត់បន្ថយបានប្រហែលជា ៤ ម៉ោង នៅពេលដែលប្រើធុងអូសកៀរដីអូសពីក្រោយ។



រូបទី៥ ការកៀរពង្រាបដីដោយត្រាក់ទ័រ

### ២.៤ វិធីកៀរពង្រាបដីដោយប្រើត្រាក់ទ័រភ្ជាប់ប៉ែលកៀរដីពីមុខ

(4-wheel tractor using rear mounted leveling blade)

ត្រាក់ទ័រមានប៉ុងមុខភ្ជាប់ប៉ែលកៀរដីពីមុខ គឺត្រូវបានគេនិយមចូលចិត្តប្រើនាពេលបច្ចុប្បន្ននៅកម្ពុជា ដោយសារវាប្រើប្រាស់មានប្រសិទ្ធភាពខ្ពស់ក្នុងការកៀរពង្រាបដីទួលទាបៗ ឬរំលាយភ្លឺស្រែសម្រាប់ការបញ្ចូលស្រែចូលគ្នានៅក្នុងទឹក ឬដីសើមបាន និងអាចបំពាក់រ៉ូតាវ៉ាទ័រពីក្រោយត្រាក់ទ័រវាយបំបែកដីបានទៀតផង។ ជាទូទៅត្រាក់ទ័រត្រូវបានបំពាក់រ៉ូតាវ៉ាទ័រវាយដីនៅពីក្រោយនិងភ្ជាប់ប៉ែលកៀរដីពីមុខ ប៉ុន្តែទោះជាយ៉ាងណា វាមិនអាចធ្វើការកៀរពង្រាបដីឱ្យបានរាបស្មើល្អនោះទេ។



រូបទី៦ ការកៀរពង្រាបដីដោយត្រាក់ទ័រភ្ជាប់ប៉ែលកៀរដីពីមុខ

### ២.៥ ប៊ូលដូហ្ស៊ែរ (Bulldozer)

ប៊ូលដូហ្ស៊ែរ គឺប្រើប្រាស់មានប្រសិទ្ធភាពខ្ពស់ក្នុងការឈូសពង្រាបដីទួល "សណ្ឋានដីទឹករលក" (undulated) សម្រាប់ការងារពង្រាបដីដំបូងលើទីវាលធំៗ ពិសេសក្នុងករណីកន្លែងដីនោះសម្បូណ៌ទៅដោយថ្មនិងជាដីរឹង។ ទោះជាយ៉ាងណា វាមិនមែនគេមើលឃើញថាជាដំណោះស្រាយដ៏ល្អឥតខ្ចោះដើម្បីកៀរពង្រាបដីឱ្យបានសុក្រឹតនោះទេ។ ការកៀរពង្រាបដីឱ្យបានសុក្រឹត អាចត្រូវបានសម្រេចដោយប្រើបច្ចេក

វិទ្យាជឿនលឿនមួយ(ដូចជាការអនុវត្តន៍បច្ចេកវិទ្យាឡាស៊ែរដែរ) ហើយនឹងត្រូវបានរៀបរាប់ដូចខាងក្រោមនេះ ដោយគ្រាន់តែបំពេញបន្ថែម និងធ្វើឱ្យដីបានរាបស្មើល្អក្រោយការឈូសពង្រាបដោយប្រើប៊ូលដូហ្សែររួច។



រូបទី៧ ការកៀរពង្រាបដីដោយប៊ូលដូហ្សែរ បំពាក់ប្រព័ន្ធឡាស៊ែរ

## ២.៦ ត្រាក់ទ័រមានប៉ុងមុខ បំពាក់ជាមួយធុងកៀរដីឡាស៊ែរ

(4-wheel tractor with a laser-controlled bucket)

ការប្រើប្រាស់ឧបករណ៍កៀរដីដោយឡាស៊ែរ (laser controlled equipment) ទទួលបានលទ្ធផលច្រើនរហូតដល់ទៅ៨០% បានល្អប្រសើរជាងការកៀរពង្រាបដីដោយប្រើបច្ចេកទេសផ្សេងៗទៀត។ បច្ចេកវិទ្យាប្រព័ន្ធបញ្ជាកាំរស្មីឡាស៊ែរ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយជាយូរឆ្នាំមកហើយនៅក្នុងវិស័យឧស្សាហកម្ម។ ដោយសារភាពងាយស្រួលនិងភាពសុក្រឹតរបស់វា បច្ចុប្បន្នកំពុងត្រូវបានគេនិយមចូលចិត្តប្រើប្រាស់នៅក្នុងវិស័យកសិកម្មផងដែរ។ បច្ចេកវិទ្យាប្រព័ន្ធបញ្ជាកាំរស្មីឡាស៊ែរ បានកែលម្អឱ្យមានភាពកាន់តែសុក្រឹតនិងមានប្រសិទ្ធភាពលើកិច្ចប្រតិបត្តិការនានាក្នុងវិស័យកសិកម្ម កាត់បន្ថយបានតម្រូវការកម្លាំងពលកម្មផងដែរ។ ជាក់ស្តែងបច្ចេកវិទ្យាប្រព័ន្ធបញ្ជាកាំរស្មីឡាស៊ែរ ត្រូវបានគេកំពុងប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ការងារកៀរពង្រាបដីកសិកម្មជាមួយត្រាក់ទ័រ។ ចំពោះគោលការណ៍នៃការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរគឺ៖

១. ចំណាយពលកម្មនិងពេលវេលាតិច
២. កំណត់ភាពខ្ពស់ទាបនៃដី(ដោយការវាស់ស្ទង់) រួចកៀរពីខ្ពស់មកទាប
៣. ស្រែមានទឹក គឺកៀរពីកន្លែងខ្ពស់ជាងទឹកទៅកន្លែងលិចទឹក
៤. ស្រែគោក គឺស្ទង់ដោយឧបករណ៍ ទុយោទឹក អ៊ុបទិច និងឡាស៊ែរ។

ជាទូទៅការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរមានវិធីពីររបៀបគឺ ទី១ វិធីកៀរពង្រាបដីស្រែមានទឹក និងទី២ វិធីកៀរពង្រាបដីស្រែស្ងួត។ ប៉ុន្តែទោះជាយ៉ាងណា គេនិយមប្រើប្រាស់វិធីកៀរពង្រាបដីស្រែស្ងួតជាងដោយសារវាមានភាពងាយស្រួលនិងទទួលបានប្រសិទ្ធភាពខ្ពស់។

## ២.៧ វិធីកៀរពង្រាបដីស្រែមានទឹក (Wet Land Leveling)

ការកៀរពង្រាបដីស្រែមានទឹក ត្រូវបានគេអនុវត្តនៅក្នុងវាលស្រែភ្លាមៗមុនពេលដាំ ព្រោះ ឬស្ទូងស្រូវ។ ដើម្បីធ្វើឱ្យដីរាបស្មើផ្ទៃខាងលើ គេត្រូវភ្ជួរដីស្រែនោះជាមុន ក្នុងស្ថានដីដែលមានទឹកដក់ តិចៗដោយប្រើប្រព័ន្ធឡាហ្សែរបញ្ជាឧបករណ៍វាយច្របល់ដីភក់ (Soil Puddler) ដែលចាប់ភ្ជាប់ត្រាក់ទ័រ៣ចំណុច ដោយលើកដាក់តាមរយៈធ្នឹមដែលភ្ជាប់ជាមួយដងអែបទាបជាងគេ។ ក្នុងប្រព័ន្ធនេះ ឧបករណ៍វាយច្របល់ដីត្រូវបានបញ្ជាឱ្យផ្អៀងចុះឡើងក្នុងប្លង់២ គឺមុខនិងក្រោយ ហើយឆ្វេងនិងស្តាំ។ ចំពោះការវាយបំបែកដីស្រែមានទឹកតាមវិធីនេះ ដីស្រែមិនមានជម្រាល ឬថ្នាក់ៗទេ។





រូបទី៨ ការកៀរពង្រាបដីដោយត្រាក់ទ័រក្នុងស្រែមានទឹក

## ២.៨ វិធីកៀរពង្រាបដីស្រែស្ងួត (Dry Land Leveling)

ការកៀរពង្រាបដីស្រែស្ងួត ត្រូវបានគេអនុវត្តដោយប្រើប្រាស់ត្រាក់ទ័របំពាក់ជាមួយធុងកៀរដីពីក្រោយ។ ដំបូងគេត្រូវភ្ជួរហាលដីពី១ ទៅ២ ថ្ងៃដើម្បីឱ្យស្ងួត រួចហើយវាយអង្គប់បំបែកដីដុំៗក្នុងស្រែឱ្យសព្វជាមុនសិន ព្រមទាំងសម្អាតស្មៅនិងសំណល់ដំណាំផ្សេងៗលើដីនោះ និងច្របល់ដីឱ្យបានសព្វល្អងាយស្រួលក្នុងការកៀរពង្រាបដី។ ដីដែលនៅសើមខ្លាំងហើយមានស្មៅ ឬសំណល់ច្រើន នឹងធ្វើឱ្យធុងមិនអាចកៀរដីបានល្អ។

ជាមធ្យមគេត្រូវការពេលប្រមាណ៤ម៉ោង ដើម្បីធ្វើការកៀរពង្រាបដីស្រែ ១ហិកតា ដែលមានស្ថានភាពដីខ្ពស់ទាបខុសគ្នាប្រមាណ ១០០មីល្លីម៉ែត្រ។

## ២.៩ តម្លៃនៃការកៀរពង្រាបដី (Cost of land leveling)

ការចំណាយដំបូងនៃការកៀរពង្រាបដី ដោយជួលអ្នកម៉ៅការនិងគ្រឿងយន្តគឺវាមានតម្លៃខ្ពស់។ ការចំណាយក្នុងការកៀរពង្រាបដីប្រែប្រួលទៅតាមឋានលេខាដី (topography) ទ្រង់ទ្រាយនៃដីស្រែ និងឧបករណ៍ដែលត្រូវបានប្រើប្រាស់ដោយបន្ថែមជី ពិសេសជីផូស្វាត គឺជាការចាំបាច់នៅក្នុងកន្លែងដីដែលត្រូវបានចូកចេញអាស្រ័យលើប្រភេទដីនិងទំហំនៃដីដែលបានចូកចេញ ដោយអាចបន្ថែមពី ២៥ ទៅ ៥០ គីឡូក្រាម ជី DAP ក្នុងស្រែមួយហិកតា។ នៅពេលដែលដីស្រែត្រូវបានកៀរពង្រាបរួច បច្ចេកទេសនៃការភ្ជួរដីត្រូវតែផ្លាស់ប្តូរ ដើម្បីរក្សាដីដែលបានកៀរពង្រាបហើយនោះនៅមានភាពស្មើដដែល។ ត្រូវណែនាំនិងជំរុញឱ្យកសិករធ្វើការភ្ជួរផ្គុំ (ពីផ្នែកកណ្តាលស្រែ) ជៀសជាងការបន្តប្រើបច្ចេកទេសបែបប្រពៃណីនៃការភ្ជួររាត់ចេញ (ពីផ្នែក

ខាងក្រៅស្រែចូលទៅផ្ទៃកកណ្តាលស្រែវិញ)។ ប្រសិនបើអនុវត្តបច្ចេកទេសភ្ជួរដីបានសមស្របនោះ វាអាចរក្សាដីស្រែឱ្យបានរាបស្មើ យ៉ាងហោចណាស់ក៏រក្សាបានពី៨ ទៅ១០ឆ្នាំដែរ ទើបត្រូវធ្វើការកៀរដីស្រែឡើងវិញ ហើយបច្ចេកទេសដែលសមស្របនិងអាចរក្សាដីស្រែរាបស្មើបានយូរ គួរកំណត់យកឧបករណ៍រ៉ូតាវ៉ាទ័រនិងឧបករណ៍រនាស់ជ្រួយដីជាការចាំបាច់។ ការវាស់វែងផ្ទៀងផ្ទាត់ភាពស្មើនៃដីស្រែនៅក្នុងឆ្នាំទីពីរ និងឆ្នាំទីបី បន្ទាប់ពីបានកៀរពង្រាបរួចបានបង្ហាញថា បម្រែបម្រួលមានកម្រិតតិចតួចណាស់នៅក្នុងការធ្វើឋានលេខាដី (topography)។ កម្រិតស្មើរបស់ដីស្រែត្រូវបានរក្សា បន្ទាប់ពីដាំដំណាំបាន ពីរដង។




រូបទី៩ បច្ចេកទេសភ្ជួរដីស្រែ ក្រោយការកៀរពង្រាបរួច

## ២.១០ អត្ថប្រយោជន៍សេដ្ឋកិច្ចនៃការកៀរពង្រាបដីស្រែ (Financial benefits of land leveling)

បើទោះបីការចំណាយដំបូងនៃការកៀរពង្រាបដី គឺជាការចំណាយបន្ថែមលំហូរសាច់ប្រាក់ដែលត្រូវចំណាយរយៈពេលច្រើនឆ្នាំបានបង្ហាញថា អត្ថប្រយោជន៍សេដ្ឋកិច្ចគឺពិតជាទទួលបានមកវិញពីការកៀរពង្រាបដី(ចំណូល)។ ថ្លៃចំណាយនេះ គិតទាំងការចំណាយលើការភ្ជួរដី និងដាក់ជីបន្ថែមសម្រាប់នៅក្នុងឆ្នាំដំបូង និងឆ្នាំទីពីរ។ អត្ថប្រយោជន៍រួមបញ្ចូលទាំងការកាត់បន្ថយលើថ្លៃចំណាយកំចាត់ស្មៅបានចំនួន ៤០%។

អត្ថប្រយោជន៍ផ្សេងទៀតនិងឱកាសនៃការទទួលបានពីការកៀរពង្រាបដីឱ្យរាបស្មើនេះ គឺគ្រាប់ពូជផ្ទាល់ ការភ្ជួរដីបានទាន់ពេលវេលា ប្រមូលផលដំណាំនៅពេលទុំស្រុះគ្នា(ripened)និងការបញ្ចេញទឹកជំនន់បានឆាប់រហ័ស។ ខណៈពេលដែលកសិករក្រីក្រអាចនឹងមានបញ្ហាហិរញ្ញប្បទានមួយ ដើម្បីចុះកិច្ចសន្យាលើការកៀរពង្រាបដី វាជាការពិតដែលអាចធ្វើបានសម្រាប់កសិករទាំងអស់ ដើម្បីធ្វើការកៀរពង្រាបដីផ្នែកណាមួយនៃដីស្រែរបស់ពួកគេជារៀងរាល់ឆ្នាំ ដោយប្រើកម្លាំងសត្វពាហនៈនិងរនាស់ នៅក្នុងអំឡុងពេលវដ្តនៃការភ្ជួរដីធម្មតា (normal plowing cycle)។

## ២.១១ បច្ចេកទេសកៀរពង្រាបដីឡាហ្ស៊ែរ (Laser leveling techniques)

ដើម្បីកៀរពង្រាបដីស្រែឱ្យបានស្អាតល្អ យើងត្រូវពិនិត្យមើលស្ថានភាពដីស្រែឱ្យបានច្បាស់លាស់ជាមុនសិនដោយអនុវត្តដូចខាងក្រោម៖

១. វាស់ស្ទង់ដីស្រែមុនពេលភ្ជួរ

២. ភ្ជួរដីស្រែ រួចហាលទុក ០១ ឬ ០២ ថ្ងៃទើបល្អ(ដើម្បីឱ្យដីស្រួយ ស្រួលកៀរពង្រាប)
៣. វាយអង្គប់បំបែកដីឱ្យម៉ត់ល្អ បន្ទាប់ពីភ្ជួររួច (ចំពោះដីកណ្តោង ល្បាយដីឥដ្ឋ)
៤. កៀរពង្រាបដីស្រែដោយបរិក្ខារឡាហ៊ែរ ប្រសិនបើដីស្រែផ្ទៀងខ្លាំង ត្រូវបែងចែកស្រែជាពីរ ដោយអនុវត្តតាមវិធីដូចខាងក្រោម៖

ក) កៀររាងជារង្វង់ តែបើដីជិតពេញធុងហើយត្រូវប្រញាប់បត់ត្រង់ទៅកន្លែងទាបភ្លាមដើម្បីចាក់ដីចេញ

ខ) កៀរដីពីចំណុចខ្ពស់រួចរត់ត្រង់ទៅកន្លែងដែលទាបតែម្តង បន្ទាប់មកត្រូវអនុវត្តតាមចំណុចទី១វិញ។ ទិន្នផលការងារគឺ ៤ម៉ោង ទៅ ៨ម៉ោងក្នុង១ហិកតា អាស្រ័យនឹងទ្រង់ទ្រាយនិងកម្រិតល្អៀងនៃដីស្រែ

គ) កៀរបណ្តោយស្រែ ដោយប្រើល្បឿនត្រាក់ទ័រយឺតៗ ដើម្បីធ្វើឱ្យស្រែរាបស្មើបានល្អ

៥. វាស់ស្ទង់ដីស្រែម្តងទៀតបន្ទាប់ពីកៀររួច ដើម្បីផ្ទៀងផ្ទាត់កម្រិតលម្អៀងចន្លោះ ១០ទៅ៣០មម (ទទួលយកបាន)។

**កំណត់ចំណាំ៖**

ការកៀរពង្រាបដីស្រែដែលមានកម្រិតខ្ពស់ទាបខ្លាំងពេក នឹងបណ្តាលឱ្យបាត់បង់ស្រទាប់ដីជីជាតិនៅកន្លែងដែលបានកៀរចេញ ហើយសម្បូរជីនៅត្រង់កន្លែងទាប។ ដូច្នេះយើងត្រូវបន្ថែមជីលាមក(គោ និងជី DAP, Phosphate) នៅកន្លែងដែលបានកៀរស្រទាប់ដីចេញ។




រូបទី១០ លំដាប់ការងារអនុវត្តកៀរពង្រាបដីដោយប្រព័ន្ធឡាហ៊ែរ

## ២.១២ គ្រឿងបរិក្ខារកៀរពង្រាបដីឡាហ៊ែរ (Laser leveling Equipment)

ការកៀរដីឱ្យស្មើ តម្រូវឱ្យមានការចូកអាចម៍ដីចេញពីទីកន្លែងខ្ពស់ទៅចាក់បំពេញនៅទីកន្លែងទាបរបស់ដីស្រែទៅតាមវិធីដែលឱ្យការចំណាយមានប្រសិទ្ធភាពខ្ពស់ (most cost-effective way)។ ក្នុងស្ថានភាពភាគច្រើន ដីស្រែនឹងត្រូវបានភ្ជួរ ហើយធ្វើការវាស់ស្ទង់(topographic survey)មុនពេលចាប់ផ្តើមកៀរ

ពង្រាបដី។ ឧបករណ៍ ដែលយកមកអនុវត្តការងារ តម្រូវឱ្យមានការចាត់ថ្នាក់ថាជាគ្រឿងបរិក្ខាររកសិកម្ម (Farm Equipment) និងគ្រឿងបរិក្ខាររកៀរពង្រាបដីដោយឡាហ្សែរ (Laser Equipment)។




រូបទី១១ គ្រឿងបរិក្ខាររកៀរពង្រាបដីដោយឡាហ្សែរ

### ២.១២.១ ធុងកៀរដី (Drag bucket)

ធុងកៀរដីអាចចាប់ភ្ជាប់៣ចំណុចជាមួយត្រាក់ទ័រ ឬក៏អូសទាញដោយរបារភ្ជាប់ត្រាក់ទ័រ (drawbar)។ ប្រព័ន្ធទាញ (pull type systems) ត្រូវបានគេនិយមចូលចិត្ត ដោយវាមានភាពងាយស្រួលដើម្បីភ្ជាប់ប្រព័ន្ធអ៊ីដ្រូលីកត្រាក់ទ័រទៅនឹងប្រអប់បញ្ជាអ៊ីដ្រូលីកខាងក្រៅ (external hydraulic ram) ជៀសជាងតភ្ជាប់ទៅប្រព័ន្ធត្រួតពិនិត្យខាងក្នុង ដែលត្រូវបានប្រើដោយចំណុចចាប់៣ភ្ជាប់នឹងប្រព័ន្ធ។ ទំហំធុងកៀរដីនិងសមត្ថភាពរបស់ធុងប្រែប្រួលទៅតាមប្រភពកម្លាំងអូសទាញ។ ត្រាក់ទ័រដែលមានកម្លាំង ៦០ សេះឡើងទៅ នឹងអូសទាញធុងកៀរដីមានបណ្ដោយ ២ ម៉ែត្រ និងកម្ពស់១ម៉ែត្រ បាននៅក្នុងគ្រប់ស្ថានភាពដីស្រែ។



រូបទី១២ ធុងកៀរកៀរដីឡាហ្សែរ

### ២.១៣ គ្រឿងបរិក្ខាររបស់ឡាហ្សែរ (Laser control equipment)

គ្រឿងបរិក្ខាររបស់ឡាហ្សែរតម្រូវឱ្យមានឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរមួយ (laser transmitter) ឧបករណ៍ទទួលកាំរស្មីឡាហ្សែរមួយ (laser receiver) ប្រអប់បញ្ជាប្រើភ្លើងមួយ (Electrical control panel) និងវ៉ាល់អ៊ីដ្រូលីក (twin solenoid hydraulic valve) មួយ។




រូបទី១៣ (A) ជើងទម្រឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរ (B) ឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរ

ឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរ (laser transmission) បាញ់កាំរស្មីឡាហ្សែរ (laser beam) ) លើប្លង់ដេក ដែលត្រូវបានទទួលចាប់យក(intercepted) ដោយឧបករណ៍ទទួលកាំរស្មីឡាហ្សែរ (laser receiver) ដែលបានភ្ជាប់នៅលើធុងកៀរដី។ ប្រអប់បញ្ជា (control panel) ភ្ជាប់នៅលើត្រាក់ទ័រ ដែលទទួលសញ្ញា (signal) ពីឧបករណ៍ទទួលកាំរស្មីឡាហ្សែរ ហើយធ្វើការបើក ឬបិទវ៉ាល់ត្រួតពិនិត្យអ៊ីដ្រូលីក ដែលនឹងលើកឡើង ឬដាក់ធុងកៀរដីចុះទៅតាមស្ថានភាពដីពេលត្រាក់ទ័របើកទៅមុខ។ ។ ពេលខ្លះឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរ អាចមានសមត្ថភាពក្នុងការប្រតិបត្តិលើទីចំណោតចាប់ពី ០.០១% ទៅ ១៥% ហើយអនុវត្តការត្រួតពិនិត្យចំណោតពីរនៅក្នុងវាលស្រែ (dual controlled slope in the field)។




រូបទី១៤ (A) ឧបករណ៍ទទួលកាំរស្មីឡាហ្សែរ (laser receiver) (B) ប្រអប់បញ្ជា (control panel) (C) ម៉ែត្រវាស់នីវ៉ូដី (laseromete)

## ២.១៤ ប្រព័ន្ធបញ្ជាអ៊ីដ្រូលីក (Hydraulic Control System)

ប្រព័ន្ធបញ្ជាអ៊ីដ្រូលីក (Hydraulic Control System) របស់ត្រាក់ទ័រ គឺត្រូវបានប្រើសម្រាប់បញ្ជូនប្រេងបូមក្នុងសេរ៉ាំងសម្រាប់លើកនិងដាក់ធុងកៀរដី ហើយប្រេងបូមដែលផ្គត់ផ្គង់ដោយស្នប់បូមប្រេងអ៊ីដ្រូលីកត្រាក់ទ័រគឺត្រូវបានផ្តល់ឱ្យជាធម្មតានូវកម្រិតសម្ពាធពី ២០០០ ទៅ ៣០០០ប៉ាស្កាល់(psi)។ស្នប់បូមអ៊ីដ្រូលីក

គឺជាស្នប់បូមដែលមានបន្លាស់ទីជាក់លាក់ (positive displacement) ហើយតែងតែបូមប្រេងច្រើនជាងតម្រូវការ ប៉ុន្តែប្រេងបូមដែលនៅសល់អាចហូរត្រឡប់ទៅក្នុងធុងប្រេងបូមរបស់ត្រាក់ទ័រវិញដោយសារវ៉ាល់ដែលភ្ជាប់ក្នុងប្រព័ន្ធ(វ៉ាល់បន្ថយសម្ពាធប្រេង)។ ប្រសិនបើវ៉ាល់បន្ថយសម្ពាធប្រេងនេះមិនមានទំហំធំគ្រប់គ្រាន់ ឬក៏មានមុខងារច្រើន (malfunctions) អាច បណ្តាលឱ្យខូចដល់ប្រព័ន្ធអ៊ីដ្រូលីករបស់ត្រាក់ទ័រ។

គ្រប់ទីកន្លែងដែលអាចធ្វើទៅបាន គឺគប្បីប្រើប្រព័ន្ធបញ្ជាអ៊ីដ្រូលីកខាងក្រៅរបស់ត្រាក់ទ័រ ដែលប្រព័ន្ធនេះមានវ៉ាល់បញ្ចេញដែលសុក្រឹតស្រាប់ (Inbuilt relief valve) ។ នៅកន្លែងដែលប្រេងបូមត្រូវបានបញ្ចេញដោយផ្ទាល់ពីស្នប់បូម (pump) ទៅកាន់វ៉ាល់ (solenoid control valve) ទុយោបញ្ចេញប្រេងបូមរបស់វ៉ាល់ត្រូវតែភ្ជាប់មុនពេលចាប់ភ្ជាប់វ៉ាល់ (control valve)។ វ៉ាល់ (solenoid control valve) ពេលដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនផលិតឧបករណ៍កៀរដីដោយឡាហ្សែរ មានវ៉ាល់បញ្ចេញ (Inbuilt relief valve) ដែលដំឡើងស្រាប់។

វ៉ាល់ (solenoid control valve) ត្រួតពិនិត្យលំហូរនៃប្រេងបូមទៅប្រអប់បញ្ជាបិទបើកអ៊ីដ្រូលីក (hydraulic ram) ដែលលើក និងដាក់ចុះធុងកៀរដី។ ប្រអប់បញ្ជាបិទបើកអ៊ីដ្រូលីក(hydraulic ram) ត្រូវបានតភ្ជាប់ទៅប្រអប់បញ្ជាបិទបើក(acting ram) តែមួយឬទាំងពីរតែម្តង។ នៅពេលដែលតភ្ជាប់ជាមួយប្រអប់បញ្ជាតែមួយ នោះត្រូវតភ្ជាប់ទុយោប្រេងបូមតែមួយដែរ ទៅប្រអប់បញ្ជាបិទបើក។ រន្ធហឺយ(air breather) មួយនេះ ត្រូវបានដាក់ដើម្បីតភ្ជាប់ទៅប្រអប់បញ្ជាបិទបើកផ្សេងទៀត ដើម្បីជៀសវាងមានជាប់ធូលីនៅលើផ្នែកមិនប្រតិបត្តិរបស់ប្រអប់បញ្ជាបិទបើក។ នៅក្នុងការរៀបឱ្យដំណើរការ(configuration)ទម្ងន់នៃធុងកៀរដីត្រូវបានប្រើនៅកម្រិតទាប (lowering)។ កម្រិតដែលចង់បាននៅពេលដែលធុងកៀរដីលើកនិងដាក់ចុះ នឹងអាស្រ័យលើល្បឿនប្រតិបត្តិការកៀរដី។ ល្បឿនបើកបរកាន់តែលឿននោះ ធុងកៀរដីក៏នឹងត្រូវកែតម្រូវផងដែរ។ កម្រិតធុងកៀរដី នឹងលើកនិងដាក់ចុះ គឺពឹងផ្អែកលើបរិមាណប្រេងបូមដែលផ្គត់ផ្គង់ទៅឱ្យទុយោចែកចាយប្រេងបូម។ សម្ពាធប្រេងដែលបានកំណត់ (pressure setting) ក្នុងវ៉ាល់ នឹងផ្លាស់ប្តូរល្បឿនលើកនិងដាក់របស់វា ដោយសារវ៉ាល់បន្ថយសម្ពាធមួយ (remote relief valve) ត្រូវបានប្រើមុនវ៉ាល់បញ្ជា (controll valve)។ ក្រុមហ៊ុនផលិតឧបករណ៍កៀរពង្រាបដីឡាហ្សែរបានផ្គត់ផ្គង់វ៉ាល់បញ្ជា (control valve) មានការត្រួតពិនិត្យកែតម្រូវទាំងវ៉ាល់ជំនួយ (bypass relief valve) និងវ៉ាល់លើក និងដាក់ចុះ។ នៅពេលដែលប្រើប្រអប់បញ្ជាបិទបើកអ៊ីដ្រូលីកប្រអប់បញ្ជា (RAM) គប្បីត្រូវបានដាក់នៅស្ថានភាពមួយ ដូច្នេះតួប្រអប់បញ្ជា (RAM) ត្រូវបានតភ្ជាប់ ដូច្នេះដើម្បីរុញ "ចុច" ពីគ្រោងធុងកៀរដីជាជាងកង់ត្រួតពិនិត្យជម្រៅ (depth contro wheels)។

## ២.១៨ វ៉ាល់បញ្ជាអ៊ីដ្រូលិករបស់ត្រាក់ទ័រ (Tractor Hydraulic Control Valves)

ប្រព័ន្ធបញ្ជាអ៊ីដ្រូលិករបស់ត្រាក់ទ័រ មកពីចំណុចកណ្តាលនៃប្រព័ន្ធបើក ឬបិទក៏បាន។ នៅពេលទទួលពីប្រព័ន្ធនីមួយៗ គឺខុសគ្នាពីការតភ្ជាប់ត្រាក់ទ័រទៅវ៉ាល់ត្រួតពិនិត្យ (control valve) ត្រូវតែរៀបចំវាឡើងវិញ។



រូបទី១៥ ប្រព័ន្ធអ៊ីដ្រូលីកបើកកណ្ដាល (Open center Hydraulic System)

## ២.១៦ ការវាស់ស្ទង់ដោយឡាស៊ែរ (Laser Surveying)

### ២.១៦.១ គ្រឿងបរិក្ខារឡាហ្វែរ (Laser Equipment)

ប្រព័ន្ធបញ្ជាកាំរស្មីឡាហ្វែរ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយជាយូរឆ្នាំមកហើយនៅក្នុងវិស័យឧស្សាហកម្ម។ បច្ចុប្បន្នបច្ចេកវិទ្យានេះ ដែលឥឡូវកំពុងត្រូវបានគេប្រើយ៉ាងទូលំទូលាយសម្រាប់គោលដៅវាស់ស្ទង់ដីដោយឡាហ្វែរនៅក្នុងវិស័យកសិកម្មផងដែរ លើការកៀរពង្រាបដីឱ្យបានស្មើល្អ។




រូបទី១៦ បរិក្ខារវាស់នីវ៉ូដី

ប្រព័ន្ធវាស់ស្ទង់ឡាហ្វែរ គឺត្រូវបានបង្កើតឡើងដោយឧបករណ៍បញ្ជូនកាំរស្មីឡាហ្វែរមួយ ជើងទម្រមួយ (tripod) ម៉ែត្របន្ទាត់មួយ (measuring rod) និងឧបករណ៍ទទួលកាំរស្មីឡាហ្វែរ (laser receiver) តូចមួយ។ គុណសម្បត្តិមួយដ៏សំខាន់នៃការវាស់ស្ទង់ឡាហ្វែរ គឺជាភាពសុក្រឹត ភាពសាមញ្ញនៃការប្រើប្រាស់ និងមនុស្សម្នាក់តែប៉ុណ្ណោះដែលត្រូវការ។

### ២.១៦.២ គ្រឿងបរិក្ខារផ្សេងទៀតដែលអាចត្រូវការ (Other equipment that may be required)

គ្រឿងបរិក្ខារផ្សេងទៀតអាចត្រូវការជាចាំបាច់នៅពេលដែលប្រើប្រាស់ព័ន្ធឡាហ្វែរ សម្រាប់ការវាស់ស្ទង់ដី (topographic surveying) រួមមាន៖

- ម៉ែត្រវាស់ប្រវែងខ្នាត១០០ម៉ែត្រ(One 100-meter tape) ការប្រើម៉ែត្រវាស់ធ្វើពីលោហៈ គឺវាមានភាពសុក្រឹត្យជាង រីឯម៉ែត្រដែលធ្វើពីក្រណាត់សរសៃរ (fiberglass tapes) គឺជាទូទៅមាំជាង។
- បុគ្គលិក (Staff): ប្រសិនបើម៉ែត្រវង្វាស់មួយ (measuring rod) មិនអាចរកបាន។ បុគ្គលិកនិយមចូលចិត្តប្រើម៉ែត្រ ដែលជាម៉ែត្រឈើត្រង់ដាក់ត្រង់ជាប្រភេទ (E-type, pattern)។ ពិនិត្យមើលភាពត្រឹមត្រូវលើមាត្រដ្ឋានក្រិតនៅលើម៉ែត្រដែលបុគ្គលិកកំពុងប្រើជាប្រភេទម៉ែត្រដែក ដោយសារតែបុគ្គលិកខ្លះអាចល្មៀង ១ ឬច្រើនសង់ទីម៉ែត្រ។
- ត្រីវិស័យ (Compass): ប្រសិនបើទិស និងទីតាំងស្វែងរកត្រូវបានកត់ត្រា នោះត្រីវិស័យនឹងត្រូវបានជាចាំបាច់។ ត្រីវិស័យនេះ អាចត្រូវបានប្រើដើម្បីកំណត់ភាគខាងជើងដោយម៉ាញេទិកនៅលើកម្រិត និងអនុញ្ញាតឱ្យកត់ត្រាចេញមកពីវា។
- ស្នឹងបង្គោល/ញញួរ (Pegs/Hammer): ស្នឹងបង្គោលគេនិយមលាបពណ៌ស ជាពិសេសសម្រាប់សម្គាល់ចេញពីការដៅវាស់ស្ទង់មួយ ឬជាសញ្ញាសំគាល់បណ្តោះអាសន្ន។
- សៀវភៅ (Book): សៀវភៅកត់ត្រា គឺត្រូវបានទាមទារ ដើម្បីកត់ត្រាការវាស់វែងទាំងអស់និងព័ត៌មានផ្សេងទៀតដែលទាមទារដើម្បីធ្វើឱ្យយល់ពីការងារវាស់ស្ទង់ដី ដែលបានបំពេញនៅក្នុងទីវាល។ ដើម្បីកត់ត្រាលម្អិតព័ត៌មានឱ្យបានគ្រប់គ្រាន់ ដូច្នេះការវាស់ស្ទង់កម្រិតស្មើនៃដីដែលបានកៀរអាចត្រូវបានត្រួតពិនិត្យម្តងទៀត (rechecked) ប្រសិនបើចាំបាច់។ សៀវភៅកត់ត្រា គប្បីឱ្យមានទំហំតូចល្មម ដើម្បីងាយស្រួលទុកដាក់ទៅក្នុងហោប៉ៅអាវ ឬហោប៉ៅខោ។
- ខ្មៅដៃ/ជ័រលុប (Pencil/Eraser): ខ្មៅដៃ និងជ័រលុប គឺនិយមប្រើប្រាស់ជាងប៊ិចទឹក ឬប្រភេទ ប៊ិច (biro type / ballpoint) នៅក្នុងទីវាល ដែលអាចងាយស្រួលក្នុងការកែតម្រូវ ហើយនឹងមិនអស់ទឹកដូចជាប៊ិចនោះទេ នៅតែដំណើរការជាប់រហូតទោះបីជាសៀវភៅនោះសើមតាមរយៈការបែកញើសក៏ដោយ។

## ២.១៧ ការវាស់ស្ទង់នៅទីវាល (Surveying a field)

ឡាស៊ែរត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនាពេលបច្ចុប្បន្ននេះ សម្រាប់ការវាស់ស្ទង់។ វាគឺមានភាពសុក្រឹតខ្ពស់ សាមញ្ញក្នុងការប្រើប្រាស់ និងងាយស្រួលដែលអាចរកបាននៅក្នុងប្រទេសភាគច្រើន។ ការកត់ត្រាដោយឧបករណ៍ឡាស៊ែរ អាចត្រូវបានទទួលតាមរយៈកាំរស្មីរហូតដល់ទៅ ៣០០ម៉ែត្រ ពីឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ។ មនុស្សម្នាក់អាចប្រតិបត្តិបានលើឧបករណ៍ឡាស៊ែរនេះ។

## ២.១៨ ការប្រើប្រាស់ឡាស៊ែរកៀរដី (Using a laser level)

- ពេលបើកជើងទម្រ (tripod) និងកែតម្រូវទីតាំងនីមួយៗរបស់ជើងទម្រ រហូតដល់ថាសទម្រ (base plate) ស្ថិតនៅទីតាំងដើម គឺមានកម្រិតរាបស្មើ ដោយប្រើខ្សែដេក ជាភ្នែកបាញ់កាំរស្មីនាំផ្លូវ ដើម្បីឱ្យទីតាំងថាសទម្ររាបស្មើ
- ចាប់ភ្ជាប់ឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ (laser transmitter) ទៅនឹងថាសទម្រ

- ប្រសិនបើឡាហ្សែរ មិនបានធ្វើឱ្យស្មើដោយខ្លួនឯងទេ ត្រូវកែសម្រួលជើងទម្រនីមួយៗនៅលើទីតាំងថាសទម្ររបស់ឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរ ដើម្បីទទួលបានពពុះទឹកស្ថិតនៅក្នុងទីតាំងកណ្ដាលនៃរង្វង់ទាំងពីរនោះ។ ឡាហ្សែរដែលភាគច្រើននឹងមិនវិលទេ លុះត្រាតែឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរមានកម្រិតស្មើ
- នៅពេលដែលឧបករណ៍បញ្ជូនកាំរស្មីឡាហ្សែរទទួលបានកម្រិតស្មើ ហើយភ្ជាប់ឧបករណ៍ទទួលទៅឱ្យបុគ្គលិក និងសំឡេងរបស់ឧបករណ៍ត្រួតពិនិត្យ (Monitor) ចាប់ ផ្ដើមមានសកម្មភាព
- ឡាហ្សែរ គឺឥឡូវនេះរួចរាល់ស្រេចដើម្បីចាប់ផ្ដើមធ្វើការកត់ត្រាកម្រិតកម្ពស់ដី។




រូបទី១៧ ប្រព័ន្ធដំណើរការនៃឡាហ្សែរ

1. **Laser Transmitter** ជាឧបករណ៍អគ្គិសនីប្រើចរន្តភ្លើង DC-6v សម្រាប់បញ្ចេញពន្លឺកាំរស្មីបាញ់ត្រង់ស្របនិងប្លង់ដេកបញ្ជូនភ្ជាប់ទៅគ្រឿងទទួល(Receiver)
2. **Receiver** ជាឧបករណ៍ទទួលពន្លឺកាំរស្មីពី Laser Transmitter ប្រើចរន្តភ្លើងជាប់ពី Control Box ដើម្បីរុញសញ្ញាតាមខ្សែចម្លងបញ្ជូនទៅ Control Box
3. **Control Box** ជាឧបករណ៍អគ្គិសនីប្រើចរន្តភ្លើង DC-12v សម្រាប់ទទួលសញ្ញាពី Receiver ដើម្បីបញ្ជាភ្លើងបើកនិងបិទ ទៅ Hydraulic Vale សម្រាប់លើកប៉ែលនិងដាក់ប៉ែលចុះ
4. **Hydraulic Vale** ជាឧបករណ៍បង្កើនសំពាធនិងបន្ធូរសំពាពភ្ជាប់ជាមួយ Relay or Solenoid ជាមួយបណ្ដូលវ៉ាល់ ប្រើចរន្តភ្លើង DC-12v ដែលបញ្ជាភ្លើង បើកនិងបិទ ពី Control Box
5. **Scraper** ជាប៉ែលបំពាក់ពីក្រោយត្រាក់ទ័រ ដែលមានបូមលើកដាក់ដែលភ្ជាប់ជាមួយវ៉ាន់អ៊ីដ្រូលីក។

## ២.១៩ ការកត់ត្រាទិន្នន័យពីការវាស់ស្ទង់ដី (Recording survey measurements)និងគណនា

វាល់ការវាស់វែងដីទាំងអស់ គប្បីកត់ត្រាទិន្នន័យទទួលបាននៅក្នុងសៀវភៅប្រើប្រាស់នៅទីវាលមួយដែលអាចទុកដាក់យ៉ាងងាយស្រួលនៅក្នុងហោប៉ៅអាវ ឬហោប៉ៅខោ។ មានវិធីជាច្រើន ដើម្បីកត់ត្រាទិន្នន័យនៅក្នុងសៀវភៅប្រើប្រាស់នៅទីវាល ប៉ុន្តែប្រព័ន្ធប្លង់បើកចំហនៅទីវាល គឺមានភាពងាយស្រួលបំផុតនៅពេលដែលការវាស់ស្ទង់ប្រើសម្រាប់ការកៀរពង្រាបដី។

### ២.២០ ទម្រង់ប្លង់នៅទីវាល (Field plan format)

នៅពេលដែលកៀរពង្រាបដី ឬទីកន្លែងដែលមានលក្ខណៈបត់បែន (contour banks) នៅក្នុងដីស្រែជាញឹកញាប់វាមានលក្ខណៈងាយស្រួលភ័ន្តច្រឡំតិច និងដើម្បីកត់ត្រាទិន្នន័យដែលបានកត់ត្រានៅលើផែនទី ឬមាត្រដ្ឋានក្រឡាចត្រង្គមួយដែលមើលឃើញតំណាងឱ្យដីស្រែនោះ។

#### ២.២០.១ ប្លង់នៅទីវាល (Field Plan)

ចំណុចគោល (benchmark) ត្រូវបានប្រើប្រាស់ ដោយថារាល់ចំណុចនៅលើទីវាល អាចត្រូវបានផ្ទៀងផ្ទាត់ឡើងវិញ ជាអំណះអំណាងប្រសិនបើត្រូវការឱ្យមាន និងដើម្បីពិនិត្យលើភាពសុក្រឹតពីការវាស់ស្ទង់។ កម្រិតស្ទង់ដី ត្រូវបានកត់ត្រាលើផែនទីក្រឡាចត្រង្គមួយ។ ការផ្លាស់ប្តូរក្នុងរយៈកម្ពស់ ឬក៏ប្រៀបធៀបការឱ្យសញ្ញាទិន្នន័យនីមួយៗ (Individual readings) ឬក៏ការដកចេញសញ្ញាទិន្នន័យពីរយៈកម្ពស់មធ្យមនៃដីស្រែ អាចត្រូវបានកំណត់ចំណោតទទេរ។ នៅក្នុងករណីសកម្មភាពនៃការអនុវត្តការកៀរពង្រាបដី នៅកន្លែងដែលត្រូវឈូសចេញ ឬចាក់បំពេញត្រូវការចាំបាច់ នោះវាជាការប្រសើរដើម្បីប្រើប្រាស់រយៈកម្ពស់មធ្យមនៃដីស្រែជាចំណុចសំអាង។ ដើម្បីកំណត់(គោល)រយៈកម្ពស់មធ្យមនៃដីស្រែ ត្រូវបានបូកគ្រប់ចំណុចដែលបានវាស់វែងទាំងអស់ រួចចែកនឹងចំនួនចំណុចដែលបានដៅទាំងអស់។

ផែនទីថ្មីបន្ទាប់ គឺគូសបង្ហាញពីភាពខុសគ្នារវាងរយៈកម្ពស់មធ្យមនៃដីស្រែ និងកម្ពស់ដែលបានកត់ត្រារួច។ ឧទាហរណ៍ ប្រសិនបើរយៈកម្ពស់មធ្យម (mean height) មាន១.០០ម៉ែត្រ និងកម្ពស់ពិតប្រាកដ (actual height) មាន១.៥០ម៉ែត្រ នោះចំណុចទាបគឺ ០.៥០ម៉ែត្រ។ នេះ គឺជាការកត់ត្រាតួលេខតាមបែបវិជ្ជមាន និងនៅពេលកៀរពង្រាបដីនៅម្តុំនោះ ត្រូវចាក់បំពេញ។ អនុវត្តតាមបែបនេះ សម្រាប់អនុវត្តលើដីស្រែឱ្យបានពេញលេញ ផែនទីបង្ហាញដីដែលត្រូវឈូសចេញ ឬចាក់បំពេញ និងប៉ាន់ស្មានទំហំដីដែលផ្លាស់ប្តូរអាចត្រូវបានគណនា។



រូបទី១៨ ចំណុចដៅដើម្បីកំណត់ប្លង់នៅទីវាល

#### ២.២០.២ កំហុសឆ្គងដោយសារតែកំណោងផែនដី (Error due to earth's curvature)

ឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ (Laser Transmitters) ត្រូវបានគ្រោងប្រើប្រាស់សម្រាប់គម្លាតមានប្រវែងដល់៣០០ម៉ែត្រ។ ក្រៅពីគម្លាតនេះ ផ្ទៃកំណោងនៃផែនដី (the curvature of the earth) ត្រូវគិតពិចារណាផងដែរ។ កំហុសឆ្គងពីកំណោងនៃផែនដី ប៉ះពាល់ដល់ឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរនិងរបៀបដែលវាបានធ្វើការវាស់ស្ទង់ដោយឧបករណ៍។ កម្ពស់សញ្ញាកត់ត្រានូវគម្លាតឆ្ងាយ និងចេញតម្លៃទាបជាង

តម្លៃដែលពួកគេទទួលបានពិតប្រាកដមែនទែន។ តារាងខាងក្រោមនេះ បង្ហាញពីចំនួនបរិមាណនៃការខុសឆ្គងសម្រាប់សញ្ញាបាញ់ត្រង់ (a straight line of sight) ដោយសារកំណោងរបស់ផែនដី៖



| No | គម្លាតចំងាយ (m) | ចំងាយលម្អៀងនៃសញ្ញាបាញ់ត្រង់ (mm) |
|---|---|---|
| 1 | 150 | 1.5 |
| 2 | 300 | 6 |
| 3 | 450 | 15 |
| 4 | 600 | 24 |

រូបទី១៩ ដែនបាញ់ពន្លឺរបស់កាំរស្មីឡាស៊ែរ

## ២.២០.៣ កំណត់ពេលវេលាតាមទ្រឹស្តីដើម្បីកៀរពង្រាបដីស្រែ

## (Determine the theoretical time to level a field)

ថេរវេលាចំណាយលើការកៀរពង្រាបដីស្រែ អាចត្រូវបានគណនាដោយស្គាល់ពីជម្រៅជាមធ្យមនៃដីស្រែក្នុងផែនទីដែលត្រូវឈូសចេញ ឬចាក់បំពេញ(cut / fill map) ទំហំដីស្រែ (dimensions) បរិមាណនៃអាចម៍ដីដែលអាចត្រូវបានចូកចេញដោយធុងកៀរដី និងល្បឿនប្រតិបត្តិការរបស់ត្រាក់ទ័រ។

ឧទាហរណ៍សម្រាប់ការប៉ាន់ប្រមាណរយៈពេលប្រតិបត្តិការ

| បរិយាយ | របៀបគណនា | ឧទាហរណ៍ |
|---|---|---|
| ទំហំដីស្រែ | | ១០០ម៉ែត្រ x ៥០ម៉ែត្រ |
| ជម្រៅមធ្យមនៃដីដែលត្រូវចូកចេញ | | ២៥សង់ទីម៉ែត្រ |
| ទំហំរបស់ធុងកៀរដី | | ២ម៉ែត្រ x ១ម៉ែត្រ x ១ម៉ែត្រ |
| អាចម៍ដីដែលធុងកៀរដីចូកបាន | | ៥០% |
| ល្បឿនត្រាក់ទ័រ(ល្បឿនមធ្យមនៅពេលដែលធុងកៀរទទេរ ឬពេញ) | គិតជាមធ្យម | ៨គ.ម/ម៉ោង ឬ ៨០០០ម/ម៉ោង |
| បរិមាណអាចម៍ដីដែលត្រូវចូកចេញ | ផ្ទៃដីស្រែ/២ x ជម្រៅមធ្យមអាចម៍ដីចូកចេញ (ម៉ែត្រ) | ១០០ x ៥០/២ x ០.២៥=៦២៥ ម៉ែត្រគូប |

| | | |
|---|---|---|
| បរិមាណអាចម៍ដីក្នុងប៉ែលកៀរដី (ម៉ែត្រគូប) | ទំហំធុងកៀរដី x អាចម៍ដី ដែលធុងកៀរដីចូកបាន | ២x១x១x០.៥=១ម៉ែត្រគូប |
| ចំនួនសារដែលត្រូវបំពេញ | បរិមាណអាចម៍ដីដែលត្រូវចូកចេញ x ចំនួនសារ | ៦២៥/១ x ២ (ធុងកៀរដីពេញ និងធុងកៀរដីទទេរ) = ១២៥០សារ |
| ប្រវែងមធ្យមក្នុង១សារ | ៥០% នៃដីស្រែ | ១០០/២=៥០ម៉ែត្រ |
| ប្រវែងសរុបដែលបានបន្លាស់ទី(ម៉ែត្រ) | ចំនួនសារ x ប្រវែងមធ្យមក្នុង១សារ | ១២៥០x៥០ម៉ែត្រ=៦២៥០០ ម៉ែត្រ |
| តម្រូវការពេលវេលាប្រតិបត្តិកា(ម៉ោង) | ចម្ងាយ(ម៉ែត្រ) / ល្បឿន (ម/ម៉ោង) | ៦២៥០០/៨០០០=៧,៧៧ម៉ោង |

ដូច្នេះ ដើម្បីកៀរពង្រាបដីឱ្យស្មើ ទាមទារចំណាយពេល**ប្រមាណ ៨ម៉ោង**។ នេះ គឺជាពេលវេលាតាមទ្រឹស្តី នឹងមានការប្រែប្រួលទៅតាមជំនាញនៃប្រតិបត្តិករ ប្រភេទដី និងលក្ខខណ្ឌ ប្រតិបត្តិការដទៃទៀត។

### ២.២០.៤ ការពិនិត្យមើលនិងការក្រិតតាមខ្នាត (Checking and calibrating a laser transmitter)

ឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ គប្បីត្រូវបានពិនិត្យយ៉ាងទៀងទាត់សម្រាប់សុក្រឹតភាព។ ភាគច្រើននៃឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ មានវីសសម្រាប់កែតម្រូវពីផ្ទៃដេក (horizontal level) ដែលអនុញ្ញាតឱ្យកែតម្រូវបន្តិចបន្តួចដែលត្រូវបានធ្វើឡើងនៅតាមបណ្តោយអ័ក្សដេកទាំងពីរនៃផ្ទៃរាបនោះ។ អ័ក្ស គឺជាទូទៅត្រូវបានដាក់ស្លាក "X" និង "Y" ។ នីតិវិធីនៃការពិនិត្យមើល និងការក្រិតតាមខ្នាតទាំងអស់ត្រូវបានធ្វើឡើងនៅក្នុងការអានមានកម្រិតសូន្យ( at the zero slope reading)។

ដើម្បីពិនិត្យមើលភាពត្រឹមត្រូវនៃឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ គឺទាមទារដូចខាងក្រោម៖

- ដាក់ជើងទម្រ (tripod) ឱ្យបានសមរម្យ ដែលអនុញ្ញាតឱ្យអ្នកដើម្បីបង្វិលឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ(transmitter) ក្នុងការបង្កើតមុំ៩០អង្សារបន្ថែម។
- ដាក់យ៉ាងតិច ៦៥ម៉ែត្រក្នុងមួយជួរ ដែលវាមិនមានការរាំងស្ទះ(unobstructed)ហើយដែលកៀកទៅនឹងផ្ទៃរាបស្មើដូចដែលអ្នកអាចធ្វើបាន។

នីតិវិធីនៃការពិនិត្យមើល និងការក្រឹតតាមខ្នាត គឺមានដូចខាងក្រោម៖

- ដាក់ឯកតា (unit) លើឧបករណ៍ស្ទង់ដីទៅចុងម្ខាងប្រវែង ៦០ម៉ែត្រ និងពង្រាបវាឱ្យស្មើ កំណត់អ័ក្ស "X" និង "Y" ឱ្យនៅចំណុចផ្តើមសូន្យ។ ជាមួយនឹងឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរស្វ័យប្រវត្តិ (auto leveling transmitters) បង្វែរចុចទៅកាន់ទីតាំង (AUTO position) (transmitter control) និងការរង់ចាំរហូតដល់អំពូល (Auto Mode Indicator) បញ្ឈប់ពន្លឺ
- ដាក់ទីតាំងមួយ(rodman) ជាមួយនឹងឧបករណ៍ទទួលកាំរស្មីឡាស៊ែរ (receiver) នៅចុងផ្សេងទៀតឆ្ងាយពីជួរប្រវែង៦០ម៉ែត្រ

- តម្រឹមឡាស៊ែរដោយប្រើ (sighting scope) ឬចង្អូរ(groove)ដូចជា "X" ត្រូវបានចង្អុលបង្ហាញដោយផ្ទាល់នៅត្រង់(rodman)។ ត្រូវប្រាកដថាត្រូវបានបង្វិល(pentamirror) និងអំពូល (flashing)បានបញ្ឈប់លោតភ្លើងប្រសិនបើសមស្រប(Auto Mode Indicator)។
- មាន(rodman)យកការអានឱ្យសុក្រឹត (precise reading) ដើម្បីភាពជាក់លាក់ជាមួយគម្លាត ២ មម និងសម្គាល់ការអាន (reading) ជា X1
- បង្វិលមុំឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ(transmitter) ១៨០ ដឺក្រេ និងរង់ចាំយ៉ាងហោចណាស់ ២ នាទីសម្រាប់ឱ្យវាធ្វើឱ្យស្មើឡើងវិញ។ នៅលើ (non-auto leveling transmitters) ក្រិតឱ្យវាស្មើឡើងវិញដោយដៃ។ មាន(rodman) យកការអានឱ្យត្រឹមត្រូវ (accurate reading) មួយផ្សេងទៀត និងសម្គាល់ការអាន (reading) ជា X2។

### ២.២០.៥ ការរំពឹងទុក (Outcomes)

ប្រសិនបើមានភាពខុសគ្នារវាង X1 និង X2 គឺតិចជាង ៦ មិល្លីម៉ែត្រ ការកែសម្រួល គឺមិនចាំបាច់នោះទេ ហើយឡាស៊ែរ ដែលអាចត្រូវបានសន្មត់ថាបានផ្តល់ការអានដែលត្រឹមត្រូវ។ ប្រសិនបើមានភាពខុសគ្នា ចន្លោះពី ៦ ទៅ ៣៨ មិល្លីម៉ែត្រលើឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ(transmitter) នោះត្រូវការឱ្យមានក្រិតតាមខ្នាត ហើយការងារនេះអាចត្រូវបានធ្វើនៅលើទីវាលនៅកន្លែងនោះ។ សូមមើលនៅលើឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ(transmitter)។

**កំណត់ចំណាំ (Note)**៖ ប្រសិនបើមានភាពខុសគ្នា គឺចាប់ពី ៣៨ មិល្លីម៉ែត្រ ឬធំជាងខ្នាតឯកតា ត្រូវតែក្រិតខ្នាតឡើងវិញនៅឯមជ្ឈមណ្ឌលសេវាកម្មមួយដែលមានច្បាប់អនុញ្ញាតត្រឹមត្រូវ។ អ្នកមិនអាចក្រិតខ្នាតឡើងវិញ(recalibrate) នៅក្នុងទីវាលបានឡើយ ព្រោះអាចបណ្តាលឱ្យខូចខាតដល់ឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរ (Laser transmitter)។

### ២.២០.៦ ការក្រិតឧករណ៍បញ្ជូនកាំរស្មីឡាស៊ែរ (Calibration of the transmitter)

ប្រសិនបើមានភាពខុសគ្នានៅលើឧបករណ៍បញ្ជូនចន្លោះពី ៦ ទៅ ៣៨ មិល្លីម៉ែត្រ នោះឧបករណ៍បញ្ជូនកាំរស្មីឡាស៊ែរអាចត្រូវបានក្រិតនៅទីកន្លែងនោះ។

ក-នីតិវិធី (Procedure)

- ចាប់ពីការគណនាលើការអានពីមុនចំនួនពីរដង "X" average (មធ្យម) = (X1 + X2) / 2 និងមាន rodman កែតម្រូវ (detector) លើដង(rod) ទៅ "X" average (មធ្យម)។ ចំណុចកណ្តាលនៃ (detector) ចន្លោះការអានទាំងពីរ
- កំណត់ទីតាំង "X" លើវីសក្រិត និងកែតម្រូវវាដើម្បីតម្រឹមធ្នឹមទៅ "X" average (មធ្យម) លើ (detector)។ ប្រសិនបើការមួលបង្វិលលើវីសក្រិតមិនអាចតម្រឹមធ្នឹមបាន បញ្ជូនឧបករណ៍នោះទៅមជ្ឈមណ្ឌលសេវាកម្ម ដើម្បីក្រិតឡើងវិញ

- បន្ទាប់ពីការកែតម្រូវថ្មីរួច ដាក់ឧបករណ៍នោះដើម្បីឱ្យនឹង នៅមុនពេលទទួលយកការអានបន្ទាប់ រួចមកធ្វើតាមនីតិវិធីខាងលើឡើងវិញ ដើម្បីពិនិត្យមើលការងាររបស់អ្នក និងធ្វើការកែតម្រូវឡើងវិញ (readjust) ឱ្យបានល្អ ប្រសិនបើចាំបាច់ដើម្បីឱ្យវាបានត្រឹមត្រូវ
- បន្ទាប់ពីការកែតម្រូវ "X" អ័ក្សបង្វិលឧបករណ៍បញ្ចូនមុំ ៩០ដឺក្រេ ដែលបានបញ្ជូនទៅកាន់អ័ក្ស "Y"។ ដៅចំណុចអ័ក្ស "Y" ដោយផ្ទាល់នៅ rodman ដោយប្រើ (sighting scope) ឬចង្អូរ (groove) និងការធ្វើឡើងវិញនូវជំហានទាំង ៥ខាងលើ រហូតដល់ ៩។ ពិនិត្យមើលលើ Y1 និង Y2 និងគណនាតម្លៃមធ្យម "Y" អ័ក្ស ដូចដែលអ្នកបានធ្វើនៅក្នុងជំហានទី៧(លំដាប់)។

នីតិវិធីដូចគ្នាអាចនឹងត្រូវបានប្រើដោយផ្ទាល់ទៅថ្មីមនៅលើជញ្ជាំងចម្ងាយ ៦០ ម៉ែត្រ។ ជំនួសឱ្យការមានការកត់ត្រាលើ rodman គឺអាស្រ័យលើបុគ្គលិកធ្វើឱ្យមានសញ្ញានៅលើជញ្ជាំង X1 និង X2 ហើយបន្ទាប់មកគូរបន្ទាត់នៅក្នុងចំណុចកណ្តាលនោះ។ ថ្មីម គឺត្រូវបានកែតម្រូវរហូតដល់វាត្រូវបានកត់ត្រានៅឯបន្ទាត់កណ្តាល(centerline)។ប្រព័ន្ធនេះ គឺមានសារប្រយោជន៍ ប្រសិនបើមិនមាន rodman ដែលអាចប្រើបាន ឬបុគ្គលិកវាស់វែង គឺមិនអាចរកបាន។




រូបទី២០ ការវាស់កម្ពស់ដីដោយនីវ៉ូកម្ពស់ទឹកទុយយោ

❖ វិធីអនុវត្តវាស់កម្ពស់ដីដោយនីវ៉ូកម្ពស់ទឹកទុយយោ
  - ដំបូងយើងបន្ទាត់ A និង B ដាក់បញ្ឈរឱ្យស្របគ្នាក្នុងចន្លោះប្រវែង ១០ម៉ែត្រ
  - ប្តូរទីតាំងបន្ទាប់ A ដាក់ត្រង់បន្ទាត់ C
  - ប្តូរទីតាំងបន្ទាប់ B ដាក់ត្រង់បន្ទាត់ D
  - ការផ្លាស់ប្តូរទីតាំងបន្ទាត់ត្រូវអនុវត្តតាមចំនុចខាងលើទាំងពីរ

❖ គណនាចំណុចខ្ពស់ និងទាប រវាងពីរចំណុច
  - រវាងចំណុច A និង B ទទួលបានទិន្នន័យ 0.77-0.75= +0.02m លទ្ធផលបញ្ជាក់ថា សញ្ញាលេខ + នៅពីមុខលទ្ធផល មានន័យថា ចំណុច Aទាបជាងចំណុច B ដើម្បីឱ្យស្មើគ្នាត្រូវយកដីពីចំណុច B ទៅដាក់បំពេញចំណុច A ។

- រវាងចំណុច B និង C ទទួលបានទិន្នន័យ 0.81-0.72= +0.09m លទ្ធផលបញ្ជាក់ថា សញ្ញាលេខ + នៅពីមុខលទ្ធផល មានន័យថា ចំណុច Bទាបជាងចំណុច C ដើម្បីឱ្យស្មើគ្នាត្រូវយកដីពីចំណុច C ទៅដាក់បំពេញចំណុច B ។
- រវាងចំណុច C និង D ទទួលបានទិន្នន័យ 0.77-0.76= +0.01m លទ្ធផលបញ្ជាក់ថា សញ្ញាលេខ + នៅពីមុខលទ្ធផល មានន័យថា ចំណុច Cទាបជាងចំណុច D ដើម្បីឱ្យស្មើគ្នាត្រូវយកដីពីចំណុច D ទៅដាក់បំពេញចំណុច C ។
- រវាងចំណុច D និង E ទទួលបានទិន្នន័យ 0.83-0.70= +0.13m លទ្ធផលបញ្ជាក់ថា សញ្ញាលេខ + នៅពីមុខលទ្ធផល មានន័យថា ចំណុច Dទាបជាងចំណុច E ដើម្បីឱ្យស្មើគ្នាត្រូវយកដីពីចំណុច E ទៅដាក់បំពេញចំណុច D ។
- រវាងចំណុច E និង F ទទួលបានទិន្នន័យ 0.77-0.76= +0.01m លទ្ធផលបញ្ជាក់ថា សញ្ញាលេខ + នៅពីមុខលទ្ធផល មានន័យថា ចំណុច Eទាបជាងចំណុច F ដើម្បីឱ្យស្មើគ្នាត្រូវយកដីពីចំណុច F ទៅដាក់បំពេញចំណុច E ។

❖ គណនាកម្ពស់គ្រប់ចំណុចទាំងអស់ធៀបនឹងប្លង់ដេកមួយ

- កម្ពស់ចំណុច F ទៅប្លង់ដេកគឺ 0.76m (កម្ពស់ពិនិត្យឃើញចុងក្រោយ)
- កម្ពស់ចំណុច E ទៅប្លង់ដេកគឺ 0.76 + 0.01 = 077m
- កម្ពស់ចំណុច D ទៅប្លង់ដេកគឺ 0.77 + 0.13 = 0.90m
- កម្ពស់ចំណុច C ទៅប្លង់ដេកគឺ 0.90 + 0.01= 0.91m
- កម្ពស់ចំណុច B ទៅប្លង់ដេកគឺ 0.91+ 0.09 = 1m
- កម្ពស់ចំណុច A ទៅប្លង់ដេកគឺ 1 + 0.02 = 1.02m




រូបទី២១ ការវាស់សម្រាប់គណនាកម្ពស់មធ្យម

**គណនាកម្ពស់មធ្យមទៅប្លង់ដេក**

☞ យើងយកកម្ពស់គ្រប់ចំណុចទាំងអស់បូកបញ្ចូលគ្នា ហើយចែកគ្រប់ចំណុចទាំងអស់

$$\frac{1.02+1+0.91+0.90+0.77+0.76}{6} = 0.89\ m$$

## កំណត់រកកម្រាស់ដីដែលត្រូវកៀរចេញ និងកៀរចូល

☞ យើងយកកម្ពស់ដែលគណនាឃើញដកជាមួយកម្ពស់មធ្យម យើងបាន:

-ចំណុច A យើងទទួលបាន 1.02-0.89=0.13m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីទៅចាក់បន្ថែម ត្រង់ចំណុច A ក្នុងកម្រាស់ 0.13m

-ចំណុច B យើងទទួលបាន 1-0.89= 0.11m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីទៅចាក់បន្ថែមត្រង់ចំណុច B ក្នុងកម្រាស់ 0.11m

-ចំណុច C យើងទទួលបាន 0.91-0.89= 0.02m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីដកចេញត្រង់ចំណុច C ក្នុងកម្រាស់ 0.02m

-ចំណុច D យើងទទួលបាន 0.90-0.89= 0.01m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីដកចេញត្រង់ចំណុច D ក្នុងកម្រាស់ 0.01m

-ចំណុច E យើងទទួលបាន 0.77-0.89= -0.12m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីដកចេញត្រង់ចំណុច E ក្នុងកម្រាស់ 0.12m

-ចំណុច F យើងទទួលបាន 0.76-0.89= -0.13m ដែលមានន័យថា

ដើម្បីឱ្យស្រែនោះស្មើត្រូវកៀរដីដកចេញត្រង់ចំណុច F ក្នុងកម្រាស់ 0.13m

## វិធីគណនាវាស់ស្ទង់តាមឡាហ្សែរ

ឧទាហរណ៍៖ យើងចុះវាស់ដីស្រែមួយដោយឧបករណ៍ឡាហ្សែរដែលមាន៩ចំណុចកត់ត្រាក្នុងប្លង់ខាងក្រោម:




| | | |
|---|---|---|
| A=1.2m | B=1.1m | C=1.06m |
| D=1.09m | E=1.3m | F=1.15m |
| G=1.3m | H=1.25m | L=1.07m |

## គណនានីវ៉ូដីមធ្យមលើប្លង់ដេក

គម្លាតមធ្យមពីប្លង់ដេក គឺផលបូកគ្រប់ចំណុចទាំងអស់ទៅនឹងប្លង់ដេក ចែកនឹងចំនួនគ្រប់ចំណុចទាំងអស់ដែលវាស់បាន :

$$\frac{A+B+C+D+E+F+G+H+L}{\text{ចំនួនចំណុចដែលវាស់}} = \text{នីវ៉ូដីមធ្យម}$$

$$\frac{1.2\,m+1.1\,m+1.06\,m+1.09\,m+1.3\,m+\,1.15\,m\,+1.3\,m\,+1.25\,m+1.07\,m}{9}=1{,}168\,m$$

**គណនាកម្រាស់ដីត្រូវកៀរចេញ (-) និងកៀរចូល (+)**

- សម្រាប់ចំណុច **A** =1.2m - 1.168m = 0.032m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីទៅដាក់បន្ថែមត្រង់ចំណុច A កម្រាស់ 0.032m ។
- សម្រាប់ចំណុច **B** =1.1m-1.168m=-0.068m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីចេញពីចំណុច B កម្រាស់ 0.068m ។
- សម្រាប់ចំណុច **C** =1.06m-1.168m=-0.108m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីចេញពីចំណុច C កម្រាស់ 0.108m ។
- សម្រាប់ចំណុច **D** =1.09m-1.168m=-0.078m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីចេញពីចំណុច D កម្រាស់ 0.078m ។
- សម្រាប់ចំណុច **E** =1.3m-1.168m=0.132m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីទៅដាក់បន្ថែមត្រង់ E កម្រាស់ 0.132m ។
- សម្រាប់ចំណុច **F** =1.15m-1.168m=-0.018m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីចេញពីចំណុច Fកម្រាស់ 0.018m ។
- សម្រាប់ចំណុច **G** =1.3m-1.168m=0.132m
  ☞ តួលេខនេះបញ្ជាក់ថា ត្រូវកៀរដីទៅដាក់បន្ថែមត្រង់ចំណុច G កម្រាស់ 0.132m ។
- សម្រាប់ចំណុច **H** =1.25m-1.168m=0.082m
  ☞ តួលេខនេះបញ្ជាក់ថាត្រូវកៀរដីទៅដាក់បន្ថែមត្រង់ចំណុច H កម្រាស់ 0.082m ។
- សម្រាប់ចំណុច **L** =1.07m-1.168m=-0.098m
  ☞ តួលេខនេះបញ្ជាក់ថាត្រូវកៀរដីចេញពីចំណុច L កម្រាស់ 0.098m ។

ការសន្និដ្ឋានក្រោយពីកៀរពង្រាបដីដោយប្រព័ន្ធឡាហ្សែរ គ្រប់ចំណុចដែលបានវាស់មានកម្ពស់មធ្យមស្មើគ្នាទាំងអស់ ។ យើងអាចធ្វើការផ្ទៀងផ្ទាត់តាមរូបមន្តដូចខាងក្រោម:

កម្ពស់មធ្យមគ្រប់ចំណុច=ចំណុចវាស់មុនភ្ជួរ-កម្រាស់ដីកៀរចេញឬកម្រស់ដីកៀរចូល

-សម្រាប់ចំណុច **A** = 1.2m-0.031m = 1.169m

-សម្រាប់ចំណុច **B** = 1.1m-(-0.069m) = 1.1m+0.069m = **1.169m**

-សម្រាប់ចំណុច **C** = 1.06m-(-0.109m) = 1.06m+0.109m = **1.169m**

-សម្រាប់ចំណុច **D** = 1.09m-(-0.079m) = 1.09m+0.079m = **1.169m**

-សម្រាប់ចំណុច **E** = 1.3m-0.131m = **1.169m**

-សម្រាប់ចំណុច **F** = 1.15m-(-0.019m) = 1.15m+0.019m = **1.169m**

-សម្រាប់ចំណុច G = 1.3m-0.131m = **1.169m**

-សម្រាប់ចំណុច H = 1.25m-0.081m = **1.169m**

-សម្រាប់ចំណុច L = 1.07m-(-0.099m) = 1.07m+0.099m = **1.169m**

ខ-វាស់ចម្ងាយ (Measuring distance)

វាជាការសំខាន់ដើម្បីអាចវាស់ចម្ងាយជាច្រើន ដូចជាការសម្រេចចិត្តដ៏ពិបាកដែលត្រូវបានធ្វើឡើងនៅលើកសិដ្ឋានមួយដែលត្រូវបានផ្អែកលើលទ្ធភាព ដើម្បីវាស់ចម្ងាយដែលមានភាពត្រឹមត្រូវមួយចំនួន។ ការក្រិតឧបករណ៍ ការកំណត់នូវអត្រាអនុវត្ត (determination of application rates) ការវាស់វែងលើទិន្នផលឯកតានិងល្បឿននៃការងារប្រតិបត្តិគឺមានអថេរ(variable)មួយចំនួន ដែលពឹងផ្អែកលើការវាស់វែងចម្ងាយឆ្ងាយជាធាតុចូល។ មានវិធីជាច្រើនដើម្បីវាស់ចម្ងាយបាន។ វិធីសាស្រ្តសាមញ្ញបំផុត គឺត្រូវបានប្រើប្រាស់ខ្សែម៉ែត្រ ឬការក្រិតតាមជំហ៊ាន។

គ-វិធានវាស់វែងដោយប្រើខ្សែម៉ែត្រ (Tape measure)

វិធានវាស់វែងដោយប្រើខ្សែម៉ែត្រ គឺជាឧបករណ៍សាមញ្ញបំផុតសម្រាប់វាស់ចម្ងាយ។ ខ្សែម៉ែត្រ អាចត្រូវបានធ្វើឡើងពីដែក ពីសំឡីកែវ(fiberglass) ឬប្លាស្ទិច និងអាចប្រែប្រួលចម្ងាយប្រវែងចាប់ពី ១ម៉ែត្រ ទៅ ២០០ម៉ែត្រ។ ភាពដោយឡែកពីគ្នាភាគច្រើនកើតឡើងនៅពេលផ្លាស់ប្តូរពីទីតាំងនីមួយៗ ការប្រើខ្សែម៉ែត្រមានប្រវែងវែង នឹងមានភាពសុក្រឹតច្រើនលើការវាស់ចម្ងាយ។

ការយកចិត្តទុកដាក់ ត្រូវបានប្រើនៅត្រង់ចំណុចចាប់ផ្តើមនៃខ្សែម៉ែត្រ។ នៅលើម៉ែត្រខ្លះ វានឹងមានជាម៉ែត្រលោហៈ រុំជាកង និងម៉ែត្រខ្លះទៀត វានឹងមានកន្លែងដែលអាចឱ្យម៉ែត្ររត់រុំចូលបានត្រឹមត្រូវ។

ម៉ែត្រដែក(លោហៈ) នឹងកាន់តែមានភាពត្រឹមត្រូវជាងម៉ែត្រដែលធ្វើពីសម្ភារៈផ្សេងទៀត ប៉ុន្តែវាអាចត្រូវបានបត់បែនបានតិច និងរហ័សខូចនៅពេលដែលត្រូវបានប្រើប្រាស់។

ឃ-ការប្រើរង្វាស់ដោយខ្សែម៉ែត្រមួយ (Using a tape measure)

- ពិនិត្យមើលរង្វាស់ក្រិតលើខ្សែម៉ែត្រឱ្យបានរួចរាល់។ ខ្សែម៉ែត្រ ជាញឹកញាប់ខូច និងជួសជុលដែលជាធម្មតាតែងតែខ្លី(shortening) ក្រោយការជួសជុលដោយប្រការផ្សេងៗមួយចំនួន
- កាន់ដើមខ្សែម៉ែត្រនៅចំណុចដៅដំបូង និងអនុវត្តដាក់ខ្សែម៉ែត្រឱ្យបានត្រឹមត្រូវមុននឹងឈានទៅកាន់ចំណុចដៅទីពីរ
- នៅក្នុងលក្ខខណ្ឌដែលមានខ្យល់(windy) មនុស្សទីបីម្នាក់ទៀត គឺអាចចាំបាច់ដើម្បីជួយទប់ខ្សែម៉ែត្រត្រង់ចំណុចកណ្តាលឱ្យរត់ត្រង់គ្នា(ដើមខ្សែ និងចុងខ្សែ)។

ង-ជំហានក្រិតតាមខ្នាត (The calibrated step)

នៅក្នុងករណីខ្លះយើងមិនចាំបាច់ចង់ដឹងចម្ងាយពិតប្រាកដទេ។ កន្លែងដែលមានកំហុសតិចជាង ៥% គឺជាចម្ងាយអាចទទួលយកបាន ដែលគេអាចវាស់វែងដោយជំហានក្រិតតាមខ្នាតមួយ។ បុគ្គលម្នាក់មានប្រវែងជំហានផ្សេងគ្នាសម្រាប់លក្ខខណ្ឌបរិស្ថានខុសៗគ្នា ហើយដើម្បីក្រិតជំហានតាមខ្នាតមួយ បុគ្គលម្នាក់ត្រូវតែរាប់ចំនួនជំហានដែលខ្លួនបានដើរក្នុងចម្ងាយមួយ ដែលត្រូវបានគេស្គាល់នៅក្នុងលក្ខខណ្ឌបរិស្ថាន

នីមួយៗ។ ទាំងនេះនឹងប្រែប្រួលទៅតាមផ្ទៃដីខាងលើដែលយើងដើរ បញ្ហាឬឧបសគ្គរាំងផ្សេងៗនិងចំណោតទេរផងដែរ។

ច-តើធ្វើដូចម្តេចដើម្បីក្រិតខ្នាតជំហានរបស់អ្នក (How to calibrate your step)

- ដៅចម្ងាយប្រវែង ១០០ ម៉ែត្រមួយ
- ដើរក្នុងល្បឿនធម្មតា ដោយបោះជំហានឱ្យស្មើលើប្រវែង ១០០ ម៉ែត្រ នោះ ហើយរាប់ចំនួនជំហានដែលបានដើរ
- អនុវត្តដូចរបៀបខាងលើយ៉ាងហោចណាស់ក៏ពីរដង និងបើល្អជាងនេះទៀតគឺ ៤ដង
- បូកសរុបចំនួនសារនៃជំហានដែលបានដើរ (add up the total number of step) រួចចែកនិងចំនួនសារដែលបានដើរ
- លទ្ធផលនេះនឹងក្លាយទៅជាកត្តាបោះជំហានរបស់អ្នក
- បន្ទាប់មក យើងអាចធ្វើការគណនាចម្ងាយរវាងចំណុចគោល (object) ពីរ ដោយដើរក្នុងល្បឿនធម្មតា រួចរាប់ចំនួនជំហានទាំងអស់នោះ ដោយបែងចែកចំនួនជំហានទាំងនោះទៅនឹងកត្តាបោះជំហានរបស់អ្នក។

ឧទាហរណ៍៖ ចំងាយប្រវែង ១០០ម៉ែត្រ ខ្ញុំដើរបានចំនួន ១០៧ជំហាន។ ខ្ញុំបានដើរត្រឡប់មកវិញសារជាថ្មីលើ ១០០ម៉ែត្រ ហើយពេលនោះខ្ញុំបានដើរចំនួន ១១៣ជំហាន

- ចំនួនជំហានសរុបរបស់ខ្ញុំទាំងការដើរទៅនិងការដើរត្រឡប់មកវិញនេះគឺ ២២០ជំហាន ហើយខ្ញុំបានដើរ ២០០ម៉ែត្រ
- ដោយយកចំងាយ ២០០ម៉ែត្រ ចែកនឹងចំនួន២២០ជំហាន លទ្ធផលបាន ០.៩១ ម៉ែត្រ/ជំហាន
- អាស្រ័យហេតុនេះប្រសិនបើចម្ងាយរវាងចំណុចគោល (object) ពីរ គឺមាន ៤០ជំហាននៃការដើរទៀងទាត់របស់ខ្ញុំ ចម្ងាយពិតប្រាកដគឺ ៤០ x ០.៩១ ដែលប្រហាក់ប្រហែលទៅនឹង ៣៦.៤ ម៉ែត្រ។

## ២.២១ ការកៀរដីដោយឡាហ្សែរ ប្រតិបត្តិការលើទីវាល (Laser Leveling - Field Operation)

ការកៀរដីដោយឡាហ្សែរដែលតម្រូវឱ្យអាចម៍ដីត្រូវបានផ្លាស់ប្តូរពីកន្លែងខ្ពស់ៗ មកដាក់កន្លែងទាបៗតាមវិធីដែលភាគច្រើនជាការចំណាយមានប្រសិទ្ធភាព (cost-effective way)។ ក្នុងស្ថានភាពភាគច្រើនដីស្រែនឹងត្រូវបានភ្ជួរ ហើយធ្វើឋានលេខាដី(topographic) មុនពេលចាប់ផ្តើមកៀរពង្រាបដី។

### ២.២១.១ ការភ្ជួរស្រែ (Plough the field)

ការភ្ជួរស្រែ គេនិយមចូលចិត្តភ្ជួរវិត្ថុំ (ភ្ជួរឆ្វេង)។ ម្យ៉ាងទៀត គេនិយមចូលចិត្តភ្ជួរស្រែ ពេលដីនៅសើម ព្រោះថា ប្រសិនបើភ្ជួរស្រែពេលដីស្ងួត វាត្រូវការចំណាយថាមពលត្រាក់ទ័រច្រើន ហើយជាលទ្ធផលគឺមានអាចម៍ដីធំៗ (large clod size)។ ប្រសិនបើដីនោះវាស្ងួតខ្លាំងពេក គេត្រូវប្រើនង្គ័លថាស (one way disc) ឬនង្គ័លផ្ទៀង (moldboard) ដើម្បីភ្ជួរ។ រនាស់ថាស (disc harrows) ឬ នង្គ័លធ្មេញ (disc tine) គឺល្អសម្រាប់ការងារលើកទីពីរបន្ទាប់ពីភ្ជួររួច។ កាកសំណល់លើផ្ទៃដីចាំបាច់ត្រូវកាត់ផ្តាច់ ឬយកចេញ ដើម្បីអាចម៍ដីងាយហូរចេញពីធុងកៀរដី។

### ២.២១.២ ការកត់ត្រាការអង្កេតឋានលេខាចំណុចខ្ពស់និងទាបនៃដី
(Topographic survey recording the high and low spots)

- ការអង្កេតឋានលេខាដីដោយប្រើឡាស៊ែរ នឹងត្រូវបានអនុវត្តដើម្បីបង្កើតតំបន់ខ្ពស់និងទាបនៅក្នុងស្រែ
- ដ្យាក្រាមដីស្រែមួយ គួរតែត្រូវបានគូរសម្គាល់តំបន់ខ្ពស់និងទាបនៅក្នុងស្រែនោះ។ ចំពោះតួលេខដែលបានធ្វើអង្កេត (surveyed readings) កម្ពស់មធ្យមរបស់ស្រែនោះត្រូវបានកំណត់។ ដោយយកផលបូកនៃចំនួនលេខដែលបានធ្វើអង្កេតទាំងអស់ ហើយចែកនឹងចំនួនដង (សារ) នៃលេខដែលបានធ្វើអង្កេតទាំងអស់នោះ
- ដ្យាក្រាមស្រែមួយដោយស្គាល់កម្ពស់មធ្យមរបស់វានោះ បន្ទាប់មក យុទ្ធវិធីមួយត្រូវបានកំណត់ដើម្បីកៀរដីពីកន្លែងខ្ពស់ទៅកន្លែងទាបដោយមានប្រសិទ្ធភាពខ្ពស់បំផុត។



រូបទី២២ ការអនុវត្តន៍វាស់ស្ទង់ដីដោយគ្រឿងបរិក្ខារឡាស៊ែរ

### ២.២១.៣ ការចាប់ផ្ដើមកៀរពង្រាបដី (Begin leveling)

- ធុងកៀរដីដែលបញ្ជាដោយឡាស៊ែរ (laser-controlled bucket) ត្រូវដាក់នៅចំណុចដែលតំណាងឱ្យកម្ពស់មធ្យមរបស់ស្រែដែលត្រូវកៀរពង្រាប
- ឡាមធុងកៀរដី (blade) ត្រូវដាក់បង្ហើបប្រមាណ១-២សង់ទីម៉ែត្រលើចំណុចដែលតំណាងឱ្យកម្ពស់មធ្យមនៃដីស្រែ
- បន្ទាប់មក ត្រូវបើកត្រាក់ទ័រក្នុងទិសដៅរាងជារង្វង់មួយដែលចាប់ពីកន្លែងខ្ពស់ទៅកន្លែងទាបជាងនៅក្នុងស្រែដែលត្រូវកៀរពង្រាបនោះ
- ដើម្បីឱ្យការងារមានប្រសិទ្ធភាពខ្ពស់ នៅពេលធុងកៀរមានអាចម៍ដីជិតពេញហើយនោះ អ្នកបើកត្រូវបត់ត្រាក់ទ័ររួចបើកឆ្ពោះទៅរកកន្លែងដែលទាបជាងដើម្បីចាក់អាចម៍ដីចេញ។ ដូចគ្នាដែរ តាមឆាប់អាចធ្វើបាន នៅពេលដែលអាចម៍ដីធ្លាក់ជិតអស់ពីធុងកៀរដីហើយនោះ ត្រាក់ទ័រត្រូវបត់ រួចបើកឆ្ពោះទៅកន្លែងដីខ្ពស់ជាងគេវិញ។



រូបទី២៣ សកម្មភាពចាប់ផ្ដើមកៀរពង្រាបដីដោយឡាហ្សែរ

- នៅពេលដែលដីស្រែទាំងមូលត្រូវបានកៀរគ្របដណ្ដប់មានសណ្ឋានរាងជារង្វង់ហើយនោះ បន្ទាប់មកត្រាក់ទ័រត្រូវអូសធុងកៀរពង្រាបដីដោយបើកបណ្ដោយដីស្រែ ពីផ្នែកខាងខ្ពស់ទៅផ្នែកខាងទាបជាងនៃស្រែ
- បន្ទាប់មកត្រូវវាស់អង្កេតមើលដីស្រែឡើងវិញ ដើម្បីធ្វើឱ្យប្រាកដថាភាពស្មើនៃដីស្រែគឺអាចទទួលយកបាន
- នៅកន្លែងដីស្រែសើម គឺជាកន្លែងដែលត្រាក់ទ័រអូសទាញខ្សោយឬក៏អាចជាប់ផុង (bogging) ដូច្នេះត្រូវយកចិត្តទុកដាក់ដោយបើកត្រាក់ទ័ររាងជារង្វង់អូសដីពីជ្រុងណាមកចាក់បំពេញកន្លែងសើមនោះ
- ប្រសិនបើគេភ្ជួរដីស្រែទាំងនោះពេលដីគោក ហើយការកៀរពង្រាបដីដែលគេបានអនុវត្តល្អនៅឆ្នាំទីពីរ ដីស្រែទាំងនោះមិនតម្រូវឱ្យមានការងារកៀរពង្រាបបន្ថែមទៀតទេ យ៉ាងហោចណាស់ក៏ ៨ឆ្នាំទៀតដែរ។

## ២.២២ ការថែទាំ ឬការជួសជុលភ្លឺស្រែ (Maintain or repair levee)

ក្រោយការកៀរពង្រាបដីរួច ភ្លឺស្រែមួយចំនួនត្រូវបានរំលាយបញ្ចូលគ្នា ឬក៏បំបែកជាពីរ ដែលទាមទារឱ្យមានការថែទាំ ឬក៏ធ្វើការជួសជុលភ្លឺស្រែឡើងវិញឱ្យបានរឹងមាំល្អ និងទប់ស្កាត់ការជ្រាបលិចទឹក។ ម្យ៉ាងវិញទៀត ក្នុងពេលអនុវត្តការកៀរពង្រាបដីស្រែ ដីនៅជាប់ភ្លឺស្រែក៏មិនទាន់បានស្អាតល្អផងដែរ។

**តារាងទី២** ការជួសជុលកែសម្រួលឧបករណ៍កៀរពង្រាបដីដោយឡាហ្សែរ

| បញ្ហា (Problem) | មូលហេតុ/ដំណោះស្រាយ (Cause/Solution) |
|---|---|
| ធុងកៀរដីនឹងមិនលើក ឬដាក់ចុះ | • ពិនិត្យមើលឧបករណ៍បញ្ជូន (transmitter) កំពុងធ្វើការ<br>• ពិនិត្យមើលចំនួនវ៉ុល(vol) និងស្នឹមក្បាលអាគុយ<br>• ពិនិត្យមើលទុយោប្រេងបូមតភ្ជាប់អ៊ីដ្រូលីក<br>• ពិនិត្យមើលខ្សែភ្លើងអគ្គិសនីតភ្ជាប់នៅលើ (Hydraulic valve solenoid) |

| | |
|---|---|
| | • ពិនិត្យមើលវ៉ាល់បន្ធូរសម្ពាធប្រេងចេញ ដែលដាក់លើវ៉ាល់ត្រួតពិនិត្យ<br>• ពិនិត្យមើលតម្រងនិងកំរិតប្រេងបូមអ៊ីដ្រូលីកត្រាក់ទ័រ |
| ធុងកៀរដីមិនធ្វើការនៅក្នុងផ្នែកជាក់លាក់ណាមួយនៃស្រែ | • ឧបករណ៍បញ្ជូនកាំរស្មី និងឧបករណ៍ទទួលកាំរស្មីមិនអាចទាក់ទងគ្នាបានដោយមានអ្វីបាំង ឬត្រូវខ្យល់ប៉ះ (Laser transmitter)<br>• Laser transmitter ឡើងកំដៅខ្លាំងពេក<br>• ឧបករណ៍បញ្ជូនកាំរស្មី (Laser transmitter) បាញ់ចំការប៊ីនត្រាក់ទ័រ (ចំណាំងផ្លាត)<br>• ឧបករណ៍បញ្ជូនកាំរស្មី និងឧបករណ៍ទទួលកាំរស្មីដាក់ខាងលើនិងក្រោមហួសដែនកំណត់ទទួល |
| ធុងកៀរដីចល័តទីទៅទិសដៅតែមួយប៉ុណ្ណោះ | • ពិនិត្យមើលទុយោប្រេងបូមតភ្ជាប់អ៊ីដ្រូលីក<br>• ពិនិត្យមើលខ្សែភ្លើងតភ្ជាប់អគ្គីសនីនៅលើសូប៉ាប់អ៊ីដ្រូលីកសូលេណូអ៊ីត(Hydraulic valve solenoid)<br>• ពិនិត្យមើលវ៉ាល់បន្ធូរសម្ពាធប្រេងចេញ ដែលបានកំណត់លើវ៉ាល់ត្រួតពិនិត្យ<br>• ពិនិត្យមើលភាពកខ្វក់ដែលស្ទះទុយោប្រេងបូម |
| ធុងកៀរដីញាក់ៗនៅពេលចាប់ផ្តើមដំបូង | • ប្រេងបូមត្រជាក់ (កក) ឬគ្មានបន្ទុកនៅក្នុងធុងកៀរ<br>• ពិនិត្យមើលការកំណត់នៃវ៉ាល់បន្ធូរសម្ពាធប្រេងចេញ<br>• ទុយោសំពាធប្រេងបូមចូលខ្យល់<br>• ពិនិត្យកំរិតប្រេងបូមក្នុងធុង |
| ធុងកៀរដីលើក និងធ្លាក់ចុះដោយស្វ័យប្រវត្តិ | • ពិនិត្យមើលភាពជិត Hydraulic valve<br>• ពិនិត្យមើលខ្សែភ្លើងតភ្ជាប់អគ្គីសនីនៅលើ Hydraulic valve solenoid<br>• ពិនិត្យមើលវេវាំងលើក និងដាក់ធុងកៀរ<br>• ពិនិត្យមើលកម្រិតប្រេងបូមនៅក្នុងប្រព័ន្ធអ៊ីដ្រូលីកត្រាក់ទ័រ |
| ដីកៀរមិនស្មើគ្នា | • បើកបរលឿនពេក<br>• ល្បឿនលើក និងដាក់យឺតពេក |
| ដីស្រែមិនមានភាពស្មើ ឬជម្រាលទេរ | • ពិនិត្យមើលភាពស្មើ ឬក្រិតដោយឧបករណ៍បញ្ជូនកាំរស្មី<br>• ដីហាប់ពេកនាំឱ្យធុងកៀរពិបាកកៀរដី |

| | |
|---|---|
| | • ភ្ជួរដីរាក់ (ផុងកៀរកល់លើដីរឹង)<br>• ដីស្រែមានស្មៅ និងកាក់សំណល់កសិកម្ម |
| អាចម៍ដីមិនចេញពីផុងកៀរដី | • ដីសើមទៅ (soil to wet)<br>• មានសារធាតុ/កាកសំណល់ផ្សេងៗច្រើនពេកនៅក្នុងដី |
| អាចម៍ដីមិនចូលទៅក្នុងផុងកៀរដី | • មានកាកសំណល់ដំណាំ/ស្មៅច្រើនពេកនៅលើផ្ទៃដី<br>• ដីហាប់ពេក |
| សំពាធប្រេងបូមត្រាក់ទ័រពុះ | • យកវ៉ានHydraulic តជាសេរីភ្ជាប់ជាមួយសំពាធប្រេងបូមត្រាក់ទ័រហើយភ្ជាប់រទុយោរន្ធវ៉ានទៅផុងប្រេងបូម ហើយចំណែករន្ធមួយទៀតតភ្ជាប់ជាមួយ Hydraulic valve solenoid<br>• បន្ទាប់មកយើងមួលសេរសំពាធប្រេងក្នុងចន្លោះ១៨០០-២០០០PSI ដែលអាចលើកផុងកៀរដីរួច ផៀបនិងសំពាធអតិបរមា របស់ Hydraulic valve solennoid។(រូបទី៣៣) |




| | ប្រព័ន្ធអ៊ីដ្រូលិក **Hydraulic** |
|---|---|
| ១ | វ៉ាន Hydraulic |
| ២ | ទុយោសំពាធខ្ពស់ (ចេញពីត្រាក់ទ័រ) |
| ៣ | ទុយោប្រេងត្រឡប់ចូលផុងបូមត្រាក់ទ័រ |
| ៤ | Hydraulic Valve Solenoid |

រូបទី២៤ ប្រព័ន្ធអ៊ីដ្រូលិក

## ៣. ការរៀបចំដី ( Land preparation )

ការរៀបចំដី គឺជាទិដ្ឋភាពដ៏សំខាន់នៃការធ្វើកសិកម្ម វាជួយជំរុញដល់ការដុះលូតលាស់បានលឿនដល់ពន្លកគ្រាប់ពូជដំណាំដែលដាំ ផ្តល់នូវខ្យល់ ទឹក និងសារធាតុចិញ្ចឹមសម្រាប់ឱ្យដំណាំដុះលូតលាស់បានល្អ។ ដំណាក់កាលនៃការរៀបចំដី ប្រែប្រួលទៅតាមប្រភេទដី និងដំណាំដែលនឹងត្រូវដាំ។ ការរៀបចំដីមិនត្រឹមត្រូវអាចបណ្តាលឱ្យមានការហូរច្រោះដី មានស្មៅដុះច្រើន ឬក៏មានទឹកដក់(ដីខ្ពស់ទាប)។ សារៈសំខាន់នៃការរៀបចំដីស្រែចម្ការមុនពេលដាំគ្រាប់ពូជ វាមានទំនាក់ទំនងដែលជិតស្និតជាមួយនឹងសំណើមដី ដែលអនុញ្ញាតឱ្យមានប្រសិទ្ធិភាពសម្រាប់ដំណុះគ្រាប់បន្ថែមទៀត។ ការភ្ជួរត្រឡប់ដី (tillage overturns) ដើម្បីការពារការដុះស្មៅ និងអនុញ្ញាតឱ្យខ្យល់និងទឹក ដើម្បីជ្រាបចូលទៅ។ វាក៏យកស្មៅដែលប្រកួតប្រជែង

ជាមួយដំណាំសម្រាប់ពន្លឺនិងសារធាតុចិញ្ចឹម។ ជី និងថ្នាំសម្លាប់សត្វល្អិតត្រូវបានបន្ថែមទៅក្នុងដី ដើម្បីផ្តល់នូវសារធាតុចិញ្ចឹមដ៏សំខាន់ដល់ដំណាំ និងការពារការខូចខាតដំណាំដោយសត្វល្អិតបំផ្លាញ។

### ៣.១ ការភ្ជួរ រាស់ដី

មុនពេលភ្ជួររាស់ យើងត្រូវពិនិត្យមើលភូមិសាស្ត្រនិងស្ថានភាពដីស្រែឱ្យបានច្បាស់លាស់ ដើម្បីជ្រើសរើសវិធីសាស្ត្រភ្ជួររាស់(ភ្ជួរផ្តុំ ភ្ជួរផាត់ចេញ)។ ការបែងចែកក្បាលងារជាការសំខាន់ ត្រូវចេះចែកក្បាលងារដើម្បីចំណេញពេលវេលានិងកាត់បន្ថយការបើកបរ ក្នុងគោលបំណងសម្រេចបាននូវប្រសិទ្ធភាពការងារខ្ពស់។ ការភ្ជួររាស់ គឺដើម្បីគាស់ត្រឡប់ ជ្រោយបំផុស បង្កប់ស្មៅ ឬជញ្ជ្រាំងទៅក្នុងដី ងាយស្រួលដល់ដំណាំចាក់ឫសបានជ្រៅល្អ មានដង្ហើមទឹក និងហាលដីបានល្អ។

### ៣.២ បច្ចេកទេសភ្ជួរ រាស់ដី

ជាទូទៅការភ្ជួររាស់នៅលើដីស្រែដែលមានភ្លឺស្រែត្រឹមត្រូវ យើងត្រូវពិនិត្យមើលស្ថានភាពដីស្រែថាតើដីស្រែនោះមានលក្ខណៈខ្ពស់ និងទាបត្រង់ចំណុចណា ប្រសិនបើស្រែនោះទាបត្រង់ចំណុចកណ្តាលយើងត្រូវជ្រើសរើសវិធីភ្ជួររាស់ផ្តុំ តែផ្ទុយទៅវិញប្រសិនបើស្រែនោះខ្ពស់ត្រង់ចំណុចកណ្តាលយើងត្រូវជ្រើសរើសវិធីភ្ជួររាស់ផាត់ចេញ។

ចំពោះការភ្ជួររាស់នៅលើដីជម្រាល យើងត្រូវភ្ជួរទៅតាមអ័ក្សទទឹងនៃជម្រាល ការអនុវត្តរបៀបនេះ គឺអាចកាត់បន្ថយការហូរច្រោះដីនិងការបាត់បង់គុណភាពដី។

ការងារភ្ជួរដីមានពីររបៀបគឺៈ

ភ្ជួរផ្តុំ : អាចម៍បំណះផាត់ចូលគ្នា គឺភ្ជួរពីក្នុងចេញមកក្រៅ(ភ្ជួរឆ្វេង)។

ភ្ជួរផាត់ចេញ : អាចម៍បំណះជះចេញមកខាងភ្លឺស្រែ គឺភ្ជួរពីក្រៅមកក្នុង(ភ្ជួរស្តាំ)។




រូបទី២៥ គំនូសបំព្រួញលើការ (A) ភ្ជួរផ្តុំ និង (B) ភ្ជួរផាត់ចេញ

ពេលភ្ជួរត្រូវលើកនិងដាក់នង្គ័លឱ្យបានស្មើគ្នានៅលើក្បាលងារ ដើម្បីចៀសវាងភ្ជួរជាន់ជានពីរដងដែលនាំឱ្យខាតពេលវេលា និងប្រេងអស់ច្រើន។ ដូច្នេះ ការភ្ជួរដីត្រូវអនុវត្តដូចខាងក្រោមៈ

១. ភ្ជួរឱ្យបានជម្រៅល្អ គឺពី១០-២០ សម ដើម្បីធានាការដាំដុះបានល្អ

២. ពេលភ្ជួរគន្លងទីមួយត្រូវភ្ជួរឱ្យបានត្រង់
៣. ពេលភ្ជួរផ្គុំ គន្លងទីពីរត្រូវភ្ជួរជាន់ជានមួយភាគបី(១/៣) លើគន្លងទីមួយដើម្បីកុំឱ្យល្វែងដី
៤. ពេលភ្ជួរផាត់ចេញ ចំពោះបណ្ដូលងារត្រូវលុបគន្លងឱ្យបានស្អាតដោយបើកឱ្យឃើតៗ
៥. ភ្ជួរដីឱ្យបានស្មើ គឺកុំឱ្យដូចរងដំឡូង
៦. ត្រូវកាត់ក្បាលងារឱ្យបានស្អាតល្អ។

ក-របៀបបែងចែកក្បាលងារ

១. ទុកផ្ទៃដីជាប់ភ្លឺទាំងបួនស្មើគ្នា គឺស្មើនឹងទំហំដែលគ្រឿងយន្តអាចបត់បាន
២. ត្រូវបែងចែកងារឱ្យបានសមស្របតាមទំហំផ្ទៃដីដែលត្រូវភ្ជួរ
៣. ក្រោយពេលភ្ជួរទំហំដីខាងក្នុងរួចហើយត្រូវកាត់ក្បាលងារ។

ខ-វិធីភ្ជួរច្រើនងារ

ផ្ទៃដីស្រែធំៗ យើងអាចចែកជាពីរ ឬបីងារ និងប្រើវិធីភ្ជួរតាមរបៀបផ្គុំឬតាមរបៀបផាត់ចេញ។ ភ្ជួរតាមវិធីនេះគ្រឿងយន្តអាចបត់ឆ្វេង ឬបត់ស្ដាំលើផ្ទៃដីស្រែតែមួយ។




រូបទី២៦ វិធីភ្ជួរតាមរបៀបផ្គុំ និងផាត់ចេញ

សំគាល់៖

**ខ១**: តាងឱ្យងារទី១ **ម១**: តាងឱ្យបណ្ដូលងារទី១
**ខ២**: តាងឱ្យងារទី២ **ម២**: តាងឱ្យបណ្ដូលងារទី២

## ៣.៣ ការវាយអង្កប់បំបែកដី

### ៣.៣.១ និយមន័យអង្កប់

អង្កប់: មានតួនាទីសម្រាប់បំបែកដី ច្របល់ដី ពូនរង កាត់បំផ្លាញស្មៅចង្រៃ និងធ្វើឱ្យដីរាបស្មើ ដែលងាយស្រួលដល់ការសាបព្រោះ។ អង្កប់មានប្រសិទ្ធភាពខ្ពស់ក្នុងការប្រតិបត្តិការលើដីសើម ដីភក់ និងដីដែលបានភ្ជួររាស់រួចហើយ។

### ៣.៣.២ បច្ចេកទេសវាយអង្កប់

១. អ្នកបើកបរត្រូវបញ្ជាត្រាក់ទ័រឬគោយន្ត ចាប់ផ្តើមវាយអង្កប់តាមបណ្តោយដីស្រែក្នុងគន្លងដំបូងរួចបត់ទៅរកគន្លងផ្នែកកណ្តាលដីស្រែ ហើយបត់ទៅផ្នែកគន្លងបន្ទាប់នៃបណ្តោយដីស្រែសាជាថ្មី និងបន្តវាយអង្កប់ ទៅផ្នែកបន្ទាប់នៃកណ្តាលដីស្រែបន្តបន្ទាប់គ្នា សម្រាប់គន្លងជុំដំបូង។ ហើយអនុវត្តចូលគន្លងថ្មីជាបន្តបន្ទាប់គ្នារហូតដល់គន្លងចាកចេញជាការស្រេច។ ការវាយអង្កប់ត្រូវបើកបរឱ្យជាន់ជានមួយភាគបី (១/៣)នៃគន្លងចាស់។ដូច្នេះយើងអនុវត្តតាមវិធីសាស្ត្រនេះរហូតដល់វាយអង្កប់សព្វលើផ្ទៃដីស្រែ ។ (រូបA)

២. ក្នុងករណីរៀបចំតម្លើងផ្នែកកាំបិតរ៉ូតាវ៉ាទ័រចាប់មកតែម្ខាង អ្នកបើកបរត្រូវបញ្ជាត្រាក់ទ័រឬគោយន្តឱ្យគន្លងទី១និងគន្លងទី២វាយផ្គុំចូលគ្នា ដោយប្រើប្រាស់ល្បឿនអោយសមស្របនោះវានឹងផ្គុំ អាចម៍ដីលើកពូនបានជារង ។ (រូបB)




រូបទី២៧ របៀបវាយអង្កប់

## ៤. សេចក្តីសន្និដ្ឋាន

ក្នុងសៀវភៅនេះផ្តល់នូវការណែនាំបច្ចេកទេសថ្មី វិធីសាស្ត្រថ្មី និងគោលការណ៍បច្ចេកវិទ្យាថ្មី ស្តីពីការកៀរពង្រាបដីស្រែឱ្យរាបស្មើដោយប្រព័ន្ធឡាស៊ែរ។ នៅក្នុងខ្សែសង្វាក់ផលិតកម្មស្រូវ ការកៀរពង្រាបដីបានត្រឹមត្រូវ គឺបានរួមចំណែកមួយក្នុងចំណោមជំហានសំខាន់ៗដំបូង ដើម្បីធ្វើឱ្យផលិតកម្មស្រូវទទួលបានទិន្នផលខ្ពស់សម្រាប់ជំរុញការនាំចេញអង្ករបានជោគជ័យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

សៀវភៅណែនាំនេះអាចត្រូវបានត្រួតពិនិត្យឡើងវិញសម្រាប់ការកែសម្រួល និងកែលម្អប្រសិនបើមាន ការចាំបាច់នៅពេលអនាគតផ្អែកលើការវិវឌ្ឍន៍របស់ស្ថានការណ៍ ឬបរិបទរបស់ប្រទេស ជាពិសេសផ្អែកលើគោលនយោបាយដែលពាក់ព័ន្ធ បទប្បញ្ញត្តិ និងច្បាប់ទាក់ទិននឹងការធានាសុវត្ថិភាពស្បៀងដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។